# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៣ ខែកុម្ភៈ លេខ ២

ព. ស. ២៤៩៣ – គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងអក្សរសាស្ត្រ និងសាសនា

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ការបណ្ដុះនិស្ស័យ . . . . . . . . . | ព្រះមហា ប៉ុង ប៉ម . . . . . | ៨៣ |
| សព្វាភាំងប្រែជាខ្មែរ (តមក) . . . . . . . | លោក ម៉ុញ - នាគ្រី . . . . . . | ៩១ |
| រឿងព្រេងភូមា (តមក) . . . . . . . . . | — សាង - សាភ៉ត . . . . . | ៩៥ |
| រឿងសាមកុក (តមក) . . . . . . . . . . | — គួ - កន . . . . . . . . | ១០៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . | — ឈឹម - ក្រសេម . . . . . | ១១២ |

**ផ្នែកសាសនា**

| | | |
|---|---|---|
| ពុទ្ធសាសនានិងត្រឹស្តសាសនា ( សន្ទិសីទ លោកវេជ្ជបណ្ឌិតមីគួត ) . . . . . . . | លោក ភ៉យ - ប៉ុក . . . . . . | ១១៨ |
| ពន្លឺអាស៊ីទ្វីប (តមក) . . . . . . . . . | លោក ភ៉យ - ប៉ុក . . . . . . | ១២២ |
| ទិដ្ឋធម្មិកត្ថកថា . . . . . . . . . . | ព្រះទេពសត្ថា ស្វ - ហាយ . . . . | ១២៦ |

**កំណត់ទិនប្បវត្តិការណ៍**

| | | |
|---|---|---|
| ពិធីទទួលសម្ដេចសង្ឃនាយក ជួន - ណាត នៅវត្តដំណាក់ ( សៀមរាប ) ( តចប់ ) | ព្រះមហាកែ - អៀង . . . . . . . | ១៣៨ |
| អនុសំវច្ឆរៈមហាសន្និបាត . . . . . . . . | ពុទ្ធសាសនបណ្ឌិត្យ . . . . . . . | ១៤១ |



មួយឆ្នាំមាន ១២ សៀវភៅ ជំឡៃជាវ . . . . . . . . . . . . . ១៤៥៛,០០

# KAMBUJASURIYA

Revu littéraire et religieuse et éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE LITTERAIRE


| | | Pages |
|---|---|---|
| Education morale . . . . . . . . | *PREAH MOHA PEUNG-PAM* . . | 83 |
| Recueil des mots traduits par la Commission Culturelle (sutie) . | *M. MENH-NAKRY* . . . . . . . | 91 |
| Contes birmans (suite et fin) . . . | *M. SANG-SAVAT* . . . . . . . | 95 |
| Histoire de SAMKOK (suite) . . . . | *OKNHA NOU-KAN* . . . . . . . | 103 |
| Histoire du Royaume du Cambodge (suite . . . . . . . . . . . . . . . . | *OKNHA CHHIM-KRASEM* . . . | 112 |


### PARTIE RELIGIEUSE


| | | |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur Migot). . . | *M. RAY-BUC* . . . . . . . . . . . | 118 |
| La Lumière de l'Asie (suite) . . . . | *M. RAY-BUC* . . . . . . . . . . | 122 |
| Dithadhammikathakatha . . . . . . . . | *PREAH DEBASATTHA SO-HAY* | 126 |


### NOTES ET CHRONIQUES


| | | |
|---|---|---|
| Réception de SON EMINENCE le Chef de la Secte Mohanikay à la pagode de Damnak (Siemreap) (suite et fin) . . . . . . . . . . . | *PREAH MOHA KER-ŒUN* . . . | 138 |
| Réunion annuelle des religieux du Cambodge . . . . . . . . . . . . . . | *INSTITUT BOUDDHIQUE* . . . . | 151 |


Prix d'un abonnement annuel comprenant 12 numéros: 145$00

ការបណ្ដុះនិស្ស័យ

# ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៉ុង-ប៉ម

*អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

## ឃុនបណ្ឌានុរក្សប៊ូ ប៉ូ សៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

---

(X)

## ពាក្យផ្ដើម

*លោកអ្នកនិរទុក្ខទាំងឡាយ! មុនដំបូង សូមអញ្ជើញអស់លោកប្រមើលមើលពួកមនុស្ស តាមក្រសែពន្លឺនៃក្រសែជាតិ ។ ដ្បិតខ្សែសម្ព័ន្ធនេះ ក្នុងច្បាប់សង្គមវិទ្យា មានគោលថា: "មនុស្សយើងជាសង្ឃភូតិ គឺជាសត្វស្រុកដែលត្រូវនៅរួមគ្នាជាពួកជាក្រុម តាំងអំពីជាគ្រួសារ ជាភូមិ ជាស្រុក ដរាបដល់ប្រទេស ហើយត្រូវជាប់ទាក់ទងគ្នាក្នុងការបន្តសមាគមផង, ទឹងញែកចេញឲ្យនៅតែម្នាក់ឯង ដោយមិនរួមគ្នា ឬមិនជាប់ទាក់ទងគ្នាពុំបាន" ។*

*មួយទៀត តាមក្រសែជាតិ ដែលអ្នកប្រវត្តិសាស្ត្រសំដែងទុកមកមានគោលថា: "មនុស្សយើងត្រូវជាប់គ្នាដោយខ្សែលោហិត ឬផៅពង្ស នឹងដោយលទ្ធិប្រវេណី ព្រមទាំងទំនៀមទំលាប់ សមគួរនឹងនៅរួមគ្នាជាពួកជាគណៈបាន ដែលហៅថា "ជាតិ", បើទុកជាបែក*

ខ្ញែកគ្នាទៅនៅក្នុងទីយ៉ាងឆ្ងាយបំផុតក៏ដោយ គង់តែមានលក្ខណៈពណ៌សម្បុរនិងភាសាពាក្យនិយាយ សំដែងឲ្យដឹងថាមានក្រសែជាតិជាប់លោហិតជាមួយគ្នាដែរ" ។

មនុស្សយើង ជាសត្វប្រសើរ មានលក្ខណៈផ្សេងអំពីសត្វតិរច្ឆាន, សូម្បីមានការបរិភោគ ការដេក ការសេពមេថុន និងការខ្លាចជាធម្មតាដូចសត្វតិរច្ឆានក៏ដោយ ក៏គង់តែមានចំណែកពិសេសជាងគ្នាបានទៀត ។ ការបរិភោគមានធម៌, ដេកមានធម៌, សេពមេថុនមានធម៌, ខ្លាចមានធម៌, នេះឯងជាគុណប្រសើររបស់មនុស្ស ដែលធ្វើមនុស្សឲ្យមានឋានៈខ្ពង់ខ្ពស់ជាងសត្វតិរច្ឆាន ដោយមានគុណធម៌ សេចក្ដីគិត សតិប្បញ្ញា ល្អនិងខ្ពង់ខ្ពស់លើសជាងសត្វតិរច្ឆាន ព្រោះបេះតាំងខ្លួនឲ្យមានចិត្តបរិសុទ្ធស្អាតប្រាសចាកគំនិតថោកទាប, មានចេតនាចង់បានសេចក្ដីចំរើនដល់ខ្លួននិងមិត្តភក្ដិពេញលោក, វៀរចាកការចិញ្ចឹមជីវិតដោយបៀតបៀនគ្នា, មិនហាន់សាច់ឈាមរបស់មនុស្សផងគ្នា, បេះស្រមោលទម្ងន់, យកចិត្តគេមកប្រៀបនឹងចិត្តយើង, យកចិត្តយើងទៅប្រៀបនឹងចិត្តគេ, បន្ថែមឋានៈ, បន្ថែមការពឹងពាក់អាស្រ័យគ្នា, មិនប្រទូសរ៉ាយ, មិនបៀតបៀនគ្នាដូចសត្វតិរច្ឆាន ទើបសមនឹងឈ្មោះថាជា "សត្វប្រសើរ" ។

សូម្បីមនុស្សយើង ចូលចិត្តនៅរួមគ្នាជាពួកគណៈ ទាំងចូលចិត្តធ្វើផ្ទះធ្វើភូមិនៅជាមួយជាអនេកអនន្តក៏ដោយ គង់មានមនុស្សខ្លះដែលមាន

ទំនងនឹងទៅជាមនុស្សល្អប្រព្រឹត្តសុចរិត មានសង្គមចរិយាចំពោះគ្នានឹងគ្នា ហើយអាចត្រឡប់ប្រព្រឹត្តទៅជាមនុស្សថោកទាប មិនមានមនុស្សធម៌, ត្រាច់ទៅបៀតបៀនមិត្តភ័ក្តិផងគ្នាវិញក៏មានខ្លះដែរ, អ្នកខ្លះបង្កជម្លោះជជែកទាស់ទែងគ្នា ដែលជាហេតុបំបាត់នូវសន្តិសុខនៃពួកគណៈ មិនគិតបណ្តុះនិស្ស័យល្អទុកជាគ្រឿងការពារខ្លួន បែរជាបណ្តោយចិត្តឲ្យប្រព្រឹត្តបៀតបៀនជនដទៃ ប្រព្រឹត្តកិរិយាមារយាទតាមគំនិតដ៏ថោកទាប, គិតតែប្រយោជន៍ផ្ទាល់ខ្លួន, មិនរមិលមើលទៅទ្រងអ្នកដទៃផង ។

មនុស្សអាក្រក់ ច្រើនតែនិយាយញុះញង់ បោកប្រាស ប្រទូស-រ៉ាយ បៀតបៀនមិត្តភ័ក្តិផងគ្នានោះ មិនមានគោលអ្វីជាគ្រឿងសំដែងឲ្យឃើញថា ផ្សេងអំពីសត្វតិរច្ឆានឡើយ ផ្សេងគ្នាតែរូបកងប៉ុណ្ណោះ នឹងតាក់ថាជាមនុស្សពេញទីក៏មិនបាន បានត្រឹមតែថាជាកាកមនុស្សឬមនុស្សអង្កាមប៉ុណ្ណោះ ។ សូមកុំភ្លេចថា “ការទំលាយគោលធម៌សម្រាប់មនុស្សក៏គឺការទំលាយខ្លួនឯង, ព្រោះមនុស្សធម៌ជាគុណដែលមនុស្សគ្រប់រូបមិនត្រូវលះបង់ឡើយ កាលបើនរជនណាមួយ លះបង់មនុស្សធម៌ចេញហើយ សូម្បីក្នុងវេលាណាក៏ដោយ អ្នកនោះឈ្មោះថា លះបង់ខ្លួនឯងដែរ” ។ ហេតុនេះ ដើម្បីរក្សាឋានៈជាសត្វដ៏ប្រសើររបស់ខ្លួនទុក ជាតិមនុស្សត្រូវតែបណ្តុះនិស្ស័យ ។ ៚

និស្ស័យគឺអ្វី? បញ្ហានេះជាខដែលយើងគួរដឹងជាដំបូង ។ និស្ស័យនោះជានាមធម៌ តាំងជាសភាពកើតឡើងជាមួយនឹងចិត្ត ស៊ិងស្និតនៅ

ក្នុងសន្តានរបស់បុគ្គលឥតមានរូបប្រាកដឡើយ ហើយនៅជិតខាងខ្លួន យើងៗ មិនងាយនឹងដឹង សូម្បីយ៉ាងនោះ យើងក៏អាចដឹងបានដោយការសង្កេតនូវសេចក្តីប្រព្រឹត្តផ្លូវកាយនឹងផ្លូវវាចា របស់មនុស្សជាលក្ខណៈ ព្រោះកាយនឹងវាចាជារូបធម៌ មានខ្លួនប្រាកដឡើងបាន ។ និស្ស័យរបស់មនុស្ស ដែលយើងនឹងដឹងប្រាកដថា ល្អឬអាក្រក់ ហើយប្រព្រឹត្តក្នុងសណ្តានណានោះ រមែងកើតឡើងអំពីការប្រព្រឹត្តផ្លូវកាយនឹងវាចារបស់ខ្លួនគេ ដោយមានចិត្តជាអ្នកបង្គាប់ឲ្យកាយវាចាបញ្ចេញនិស្ស័យក្នុងការប្រព្រឹត្តនោះ ។ ។ ចុះអ្វីឈ្មោះថានិស្ស័យ ? កិរិយា អាការរបស់បុគ្គលដែលប្រែប្រួលទៅដោយប្រការផ្សេង ៗ នោះឯង ឈ្មោះថា និស្ស័យ ។

ការគិតល្អការធ្វើល្អនឹងការនិយាយល្អ ដែលនៅអែបនែបក្នុងសន្តានតែងជាសរសៃនៅពេលថ្ងៃឲ្យមនុស្សគិត ធ្វើ និយាយ តែក្នុងរឿងដែលខ្លួនគាប់ចិត្ត ជកបដល់ការគិត ការធ្វើ នឹងការនិយាយនោះ ក្លាយទៅជាទំលាប់ជាប់នៅក្នុងសន្តានអស់មួយជីវិត ។ កិរិយាបញ្ចេញលក្ខណការរមែងចង្អុលឲ្យមនុស្សដទៃដឹង - ឃើញបានថា អ្នកនោះធ្វើឬនិយាយមានអធ្យាស្រ័យចូលចិត្តទៅក្នុងផ្លូវនោះៗ ជាប្រក្រតី នេះឯង ហៅថានិស្ស័យ ។ តាមគោលក្នុងចិត្តវិទ្យាសាស្ត្រថាៈ "យើងបណ្តុះការធ្វើ យើងនឹងបានផលគឺនិស្ស័យ, យើងបណ្តុះនិស្ស័យ យើងនឹងបានផលគឺ

លក្ខណៈ" ។ នេះសំដែងឲ្យឃើញថា: "និស្ស័យនោះកើតមកពីទំលាប់ធ្វើការផ្សេង ៗ តែបើធ្វើការទាំងនោះតែមួយដង ក៏មិនទាន់ទៅជានិស្ស័យដែរ លុះតែយើងធ្វើញយ ៗ រហូតដល់ធ្លាប់ ទើបក្លាយទៅជានិស្ស័យបាន ។ ពិតមែន! ទំលាប់ដែលកើតអំពីការធ្វើញយ ៗ ដដែល ៗ នោះ រមែងកឲ្យកើតជានិស្ស័យតែម្ដងបាន ។ និស្ស័យនេះឯង រមែងក្លាយមកជាលក្ខណភាពរបស់បុគ្គលិកៈ ។ លក្ខណៈអាក្រក់ល្អរបស់បុគ្គល បានកើតមកអំពីនិស្ស័យអាក្រក់ល្អដែលគេដាំបណ្ដុះឡើង ទុកក្នុងខ្លួនឯងទាល់តែធ្លាប់ ។ និស្ស័យរបស់មនុស្សយើង ពោលដោយកំណើត មានពីរយ៉ាងគឺ:

## ពន្ធុកម្ម និង បរិវារកម្ម

និស្ស័យដែលមានមកតាមពន្ធុកម្ម ជានិស្ស័យជាប់មក អំពីឪពុកម្ដាយតាមខ្សែលោហិត នឹងជាប់តគ្នាមកតាមលំដាប់ អំពីជីដូនជីតា មាមីងដែលរួមសែស្រឡាយជាមួយគ្នា, បើជីដូនជីតា មាតាបិតា មាមីង ថោកទាប កូនចៅក៏ថោកទាបទៅតាម បើមេបាជាមនុស្សល្អ កូនចៅក៏ល្អទៅតាមដែរ ដូចភាសិតក្នុងលោកនីតិបករណ៍ថា:

"បើមាតាហីនជាតិកើតបុត្រា បុត្រនោះមានពាភាសាទាប
បើបិតាហីនជាតិមាត្រុគាម បុត្រនោះទាបកិរិយាអាក្រក់នៅ ៗ
បើម៉ែឪហីនជាតិទាំងពីរនាក់ កូននោះអបលក្ខណ៍ទាំងពីរផ្លូវ
ទាំងកិរិយាមារយាទក៏ហ្មងសៅ តាមគន្លងម៉ែឪផ្លូវដូចគ្នា ។

បើមាតាប្រសើរកើតបុត្រា    បុត្រនោះមានភាសាពាក្យពីរោះ
បើមាតាប្រសើរឥតហ្មងមោះ    ឯបុត្តនោះប្រកបកិរិយាពិត ។
បើម៉ែឪឧត្តមទាំងពីរពង្ស    កូននោះប្រកបទ្រង់អ្នកសុចរិត
ទាំងភាសាកិរិយាភាពបណ្ឌិត    បានជាមិត្តសប្បុរសក្នុងលោកិយ" ។

និស្ស័យដែលកើតមកអំពីបរិវារកម្មនោះ គឺនិស្ស័យដែលអាស្រ័យដោយការសេពគប់ជាធំ ហើយកើតឡើងជាខាងក្រោយ ៗ ការប្រឡូកប្រឡំគ្នាវឹកវរ, ការសេពគប់នឹងគ្នាទាល់តែស្គាល់ស្និទ្ធ ហើយប្រព្រឹត្តតាម ដរាបដល់ធ្លាប់ស្ទាត់ជំនាញក្នុងហេតុនោះ ៗ ដែលធ្លុងចូលមកក្នុងជីវិតរបស់ខ្លួន ដោយបានប្រទះឃើញកិរិយាអាចាររបស់មនុស្សដទៃ ឃើញបែបទំនៀមទំលាប់ ច្បាប់ ប្រវេណី មាត្រា របៀប វិន័យរបស់ពួកគណៈ ព្រមទាំងធ្វើគំនិត សេចក្តីចេះដឹង ការចូលចិត្តរបស់ខ្លួន ដែលមានញយ ៗ រឿយ ៗ ដដែល ៗ នោះឯង ធ្វើឲ្យកើតជានិស្ស័យ មានឥទ្ធិពលក្នុងជីវិតទៅអនាគត ។

រឿង " ការបណ្តុះនិស្ស័យ " ក្នុងទីនេះ ខ្ញុំមិនបានពោលដល់ទៅការបណ្តុះនិស្ស័យដែលជាពន្ធុកម្មទេ សូមពោលសំដៅយកតែការបណ្តុះនិស្ស័យដែលមានមកអំពីវត្ថុហោមរោម ( បរិវារកម្ម ) ម្យ៉ាងប៉ុណ្ណោះ ព្រោះវត្ថុហោមរោមដែលបុគ្គលអាចមើលឃើញបាន ហិតបាន លិទ្ធបាន ចាប់កាន់បាន រមែងមានហេតុផលសំខាន់ក្រៃលែងក្នុងផ្លូវបណ្តុះនិស្ស័យ

អាចបណ្ដុះមនុស្សឲ្យមានសេចក្ដីខ្លាំងក្លាឡើងបាន, ព្រោះការសមាគមសេពគប់ ជាបច្ច័យដ៏មានឥទ្ធិពលក្រៃលែងក្នុងកិច្ចទាក់ទាញដឹកនាំការប្រព្រឹត្តិនៃអធ្យាស្រ័យ ព្រមទាំងគំនិតទិដ្ឋិឲ្យផ្ទៀងទៅបានទាំងចំណែកល្អទាំងចំណែកអាក្រក់, សូម្បីអ្នកប្រាជ្ញខាងចិត្តវិទ្យាសាស្ត្រ ក៏បានកប់រងថា: "និស្ស័យរបស់មនុស្ស ប្រែប្រួលទៅបាន ដោយអំណាចវត្ថុដែលនៅជុំវិញខ្លួនច្រើនជាងការដែលជាប់ពន្ធកម្មមកអំពីកំណើត ។

មើលចុះ! ទារកដែលកើតអំពីបុគ្គលជាន់ខ្ពស់ តែមាតាបិតាបណ្ដោយឲ្យមនុស្សថោកទាប មើលថែទាំអប់រំក្សា, ភាពជាមនុស្សល្អដែលទទួលជាប់តមកអំពីផៅពន្ធកម្ម មុខជារលាយបាត់អស់ទៅមិនមាននៅសល់ឡើយ; សូម្បីបុរាណក៏ពោលទុកថា "បើលោក-អ្នកឲ្យទាសៈចិញ្ចឹមកូនរបស់ខ្លួនហើយ, កូនទីបំផុត លោក-អ្នកនឹងមានទាសៈនៅក្នុងផ្ទះដល់ទៅពីររូប" ។ ដូច្នេះការសេពគប់មនុស្សអាក្រក់ទើបជាពិធីបណ្ដុះជីវិតក្នុងនិស្ស័យអាក្រក់ ឈ្មោះថាស្រោចជីវិតដោយទឹកក្ដៅ ការសេពគប់មនុស្សល្អ ជាពិធីបណ្ដុះជីវិតក្នុងនិស្ស័យល្អ ឈ្មោះថាស្រោចស្រប់ជីវិតដោយទឹកត្រជាក់ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់សរសើរការសេពគប់មនុស្សល្អថាជាផ្លូវនៃសន្តិសុខដ៏ថ្លៃថ្លា, ទ្រង់តិះដៀលការសេពគប់មនុស្សអាក្រក់ថា ជាគន្លងនៃសេចក្ដីវិនាសហិនហោច, ហើយទ្រង់ណែនាំយើងឲ្យស្គាល់ស្ទួន

ទៅរកតែមនុស្សល្អ ព្រមទាំងឲ្យយកគេជាគំរូ ព្រោះមនុស្សល្អ កាលយើងសេពគប់ហើយតែងតែដឹកនាំយើងទៅក្នុងផ្លូវល្អ. ទ្រង់ណែនាំយើងឲ្យចៀសវាងពីមនុស្សអាក្រក់ ទាំងទ្រង់ហាមប្រាមមិនឲ្យយកគេជាគួយ៉ាង ព្រោះមនុស្សអាក្រក់នោះ រមែងមានបំណងតែនឹងដឹកនាំយើងទៅក្នុងផ្លូវអាក្រក់តែម្យ៉ាង ត្រូវនឹងសុភាសិតថា: "គប់ពាលៗ នាំទៅរកខុស គប់សប្បុរសៗ នាំទៅរកផល" ។

ពាក្យដែលព្រះ ពុទ្ធ បានផ្ដាំថា
" បើគប់ប្រាជ្ញ ក្លៀវក្លា គង់ប្រាជ្ញបាន
បើគប់ពាល គង់ពាល នាំសាមាន្យ"
៥ ពេលមកនេះប៉ុន្មាន ពិតឥតឃ្លាត ។

កាលបើនិស្ស័យកើតមកអំពីទំលាប់ធ្វើរបស់ខ្លួនហើយ និស្ស័យនោះក៏មានទាំងល្អទាំងអាក្រក់ ។ ការធ្វើសេចក្ដីល្អរឿយៗ រហូតដល់ជាប់ដូចជាទំលាប់ក្នុងភាពជាមនុស្សល្អសុភាពទន់លំទោនស្មោះត្រង់សុចរិតនឹងកតញ្ញូជាដើម ក៏បង្កឲ្យកើតជានិស្ស័យល្អតាមទំលាប់នោះ ។ បើទំលាប់ក្នុងផ្លូវអាក្រក់ ដូចជាទំលាប់ក្នុងភាពជាមនុស្សថោកទាប អាក្រក់រឹងរូស មិនស្មោះត្រង់ ទុច្ចរិតនឹងលុបគុណគេជាដើម ក៏បង្កឲ្យកើតទៅជានិស្ស័យអាក្រក់ឡើង តាមបែបនៃទំលាប់នោះ ។ (X)

**(មាតក)**

អាចបណ្ដុះមនុស្សឲ្យមានសេចក្ដីខ្លាំងក្លាឡើងបាន, ព្រោះការសមាគមសេពគប់ ជាបច្ច័យដ៏មានឥទ្ធិពលក្រៃលែងក្នុងកិច្ចទាក់ទាញដឹកនាំការប្រព្រឹត្តិនិងអធ្យាស្រ័យ ព្រមទាំងគំនិតទិដ្ឋិឲ្យផ្អៀងទៅបានទាំងចំណែកល្អទាំងចំណែកអាក្រក់, សូម្បីអ្នកប្រាជ្ញខាងចិត្តវិទ្យាសាស្ត្រ ក៏បានកប់រងថា: "និស្ស័យរបស់មនុស្ស ប្រែប្រួលទៅបាន ដោយអំណាចវត្ថុដែលនៅជុំវិញខ្លួនច្រើនជាងការដែលជាប់ពន្ធុកម្មមកអំពីកំណើត ។

មើលចុះ! ទារកដែលកើតអំពីបុគ្គលជាន់ខ្ពស់ តែមាតាបិតាបណ្ដោយឲ្យមនុស្សថោកទាប មើលថែទាំអប់រំរក្សា, ភាពជាមនុស្សល្អដែលទទួលជាប់តមកអំពីផ្លូវពន្ធុកម្ម មុខជារលាយបាត់អស់ទៅមិនមាននៅសល់ឡើយ; សូម្បីបុរាណក៏ពោលទុកថា "បើលោក-អ្នកឲ្យទាសៈបញ្ចឹមកូនរបស់ខ្លួនហើយ, ក្នុងទីបំផុត លោក-អ្នកនឹងមានទាសៈនៅក្នុងផ្ទះដល់ទៅពីររូប" ។ ដូច្នេះការសេពគប់មនុស្សអាក្រក់ទើបជាពិធីបណ្ដុះជីវិតក្នុងនិស្ស័យអាក្រក់ ឈ្មោះថាស្រោចជីវិតដោយទឹកក្ដៅ ការសេពគប់មនុស្សល្អ ជាពិធីបណ្ដុះជីវិតក្នុងនិស្ស័យល្អ ឈ្មោះថាស្រោចស្រប់ជីវិតដោយទឹកត្រជាក់ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់សរសើរការសេពគប់មនុស្សល្អថាជាផ្លូវនៃសន្តិសុខដ៏ថ្លៃថ្លា, ទ្រង់តិះដៀលការសេពគប់មនុស្សអាក្រក់ថា ជាគន្លងនៃសេចក្ដីវិនាសហិនហោច, ហើយទ្រង់ណែនាំយើងឲ្យស្គាលស្និទ្ធ

Blocus = ការបិទគមនាគមន៍ (ការបិទផ្លូវមិនឲ្យចេញចូល)

(១៨-៨-៤០)

Ministère des Affaires Etrangères = ក្រសួងការបរទេស

Office du Crédit Populaire = មន្ទីរបងការសម្រាប់ប្រជាជន

(៤-៩-៤០)

Discours = សុន្ទរកថា

Causerie = បាឋកថា

Allocution = សង្កថា

Conférance = សន្និសីទ

Un explorateur = អ្នករុករក (អ្នករុករកអ្វីៗ ដែលមិនទាន់បានស្គាល់)

Le prix de revient = តម្លៃសរុប (ថ្លៃដើមនឹងថ្លៃជាប់បង់រួមគ្នា)

Résolution = ការសំរេចចិត្ត

(៨-៩-៤០)

Office National du Tourisme = ជាតិមន្ទីរទេសចរណ៍, ក្រុមពជការរបស់ជាតិសម្រាប់ចាត់ការខាងពួកទេសចរ

(១២-៩-៤០)

Séisme, Tremblement de terre = រញ្ជួយប្រឹថពីភូមិបាល

សព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

## លោកម៉ុញ-តាគ្រី អតីតតំណាងរាស្ត្រ រួបរួម

(តទៅ)

---

Otage = ចំណាប់ខ្មាំង

Rançon = តម្លៃលោះ

Rançonner = ទារតម្លៃលោះ

(៨-១១-៥០)

Tête de pont = ក្បាលស្ពាន (ក្បាលកងទ័ពដែលបានឆ្លងទៅត្រើយម្ខាងហើយ)

Couvre-feu = បម្រាមគោចរ (បម្រាមមានកំរិតពេលមិនឲ្យដើរទៅមកក្នុងទីដែលត្រូវប្រយ័ត្ន)

L'objectif = ទីដៅ (ទីប្រតិបត្តិការដែលអ្នកបញ្ជាការកំណត់ឲ្យ)

Poche = ទ័ពជាប់ចំណោម (ទ័ពដែលជាប់នៅក្នុងចំណោមរបស់បច្ចាមិត្រ)

Etat satellite = រដ្ឋរណប (រដ្ឋដែលនៅក្រោមឥទ្ធិពលនៃរដ្ឋណាមួយ)

Ministre Résident = អគ្គរាជទូតប្រចាំទី

Chargé d'affaires = ការធារី (ឥ. ការធារិណី) អ្នកទទួលបន្ទុក
កាន់កិច្ចការជំនួសទូត
(៣-១០-៥០)

Valise diplomatique = ហិបទូត (សំបុត្រស្នាមជាដើមដែលផ្ញើ
ទៅតាមផ្លូវទូត)

Valise des diplomates = ហិបអ្នកការទូត (ហិបដែលអ្នកការទូត
ប្រើប្រាស់ផ្ទាល់ខ្លួន)

Consul marchant = កុងស៊ុលគោចរ (កុងស៊ុលដែលមាន
ស្ថានមិនទៀងទាត់)

Consul de carrière = កុងស៊ុលអាជីព (កុងស៊ុលដែលកាន់
ការក្នុងតំណែងកុងស៊ុលជានិច្ចកាល)
(៦-១០ ៥០)

Modus Vivendi = កិច្ចសញ្ញាបណ្ដោះអាសន្ន

Veto = ទំនាស់

Incompatibilité = ការមិនចុះសំរុង

Symptôme = និមិត្តហេតុ
(១៣-១០-៥០)

(មានត)

Rénovation = បុនក្ការ (ធ្វើឲ្យបានជាថ្មីឡើងវិញ)

(១៩-៩-៥)

Arboriculture = រុក្ខវប្បកម្ម (ការញុំាងឈើឲ្យចំរើន)

Secours = ជំនួយ (បម្រុងការ)

Aide = ការជួយ, ជំនួយ

Assistance = ការសង្គ្រោះ

Régime = របប, វិធី, របៀបគ្រប់គ្រង

(២៩-៩-៥០)

Rafle = ការព័ទ្ធចាប់

Amphibie = ថលជលិកៈ (អ្វីៗដែលប្រព្រឹត្តទៅបានទាំងលើគោក ទាំងក្នុងទឹក) ។

Lettre d'agrément = សារអនុលោម (សារដែលប្រមុខរដ្ឋឆ្លើយថា យល់ព្រមឲ្យតាំងទូតបរទេសនៅក្នុងរដ្ឋរបស់ខ្លួន)

Lettre de créance = សារតាំង (សារដែលប្រមុខរដ្ឋតាំងឲ្យទូតកាន់ទៅប្រគល់ចំពោះប្រមុខបរទេស)

Lettre d'exéquatur = សារឱកាសទាន (សារដែលប្រមុខរដ្ឋបើកឱកាសឲ្យកុងស៊ុលបរទេសបំពេញការនាទី)

Envoyé extraordinaire = ប្រេសិតវិសាមញ្ញ (អ្នកដែលគេបញ្ជូនទៅដើម្បីបំពេញការពិសេសណាមួយ)

ជារឿងនាំឲ្យអ្នកអានទាំងឡាយ អាចផ្ដាប់បាននូវប្រាជ្ញារបស់ព្រះនាងផូជាម៉ាសារី ។

# រឿងដែលអាហារឲ្យផលឲ្យសិស្សស្លាប់

ក្នុងកាលក្រោយនៃដើមសករាជនេះបន្តិច នៅក្នុងស្រុកគហបតី (Gahapâti) មានមនុស្សបួននាក់ បរិបូណ៌ទៅដោយគោត្តសម្ប័ទនឹងបញ្ញា ។ ជនទាំង ៤ រូបនេះ បង្កាន់មានមេត្រីនឹងគ្នាយ៉ាងស្មោះស្ម័គ្រ ហើយយ៉ាងមាំមួនជាទីបំផុត មិនតែប៉ុណ្ណោះ ថែមទាំងបានជួយជ្រោមជ្រែងគ្នាទៅវិញទៅមកយ៉ាងរីករាយសព្វខ្លួនផង ។

លុះដល់កាលជាខាងក្រោយមក មិត្តម្នាក់ក៏ស្លាប់បាត់បង់ជីវិតទៅ តែបុរសនេះមានកូនប្រុសមួយនៅជាមួយនឹងភរិយារបស់គាត់ម្នាក់ ។ ថ្ងៃមួយស្ត្រីមេម៉ាយនេះនិយាយទៅកាន់បុត្រថា : "កូនសំណព្វសំឡាញ់មាសម្ដាយអើយ! ឪពុកអ្នកស្លាប់បាត់បង់ជីវិតទៅហើយ ហេតុដូច្នេះមានតែកូនទេ ដែលអាចនឹងកាន់កាប់ការជំនួសជាមេផ្ទះនេះបាន; ចាប់តាំងពីថ្ងៃស្អែកទៅ កូននឹងមានអំណាចពេញទីលើទ្រព្យសម្បត្តិទាំងអស់, ប៉ុន្តែកូននៅក្មេងសេចក្ដីណាស់ កូនមិនទាន់មានសន្ដិចរិយានឹងស្មារតី ដែលជាវត្ថុមួយយ៉ាងសំខាន់នៅនាលោកនេះនៅឡើយទេ, ហេតុដូច្នេះ គោងកូនទៅរកមិត្តសំឡាញ់ទាំងបីនាក់របស់ឪពុកកូន ដើម្បីសុំរៀនជំរះវិជ្ជាពីគេឲ្យបានយូរបន្តិចទៅ"; ថាហើយនាងដាក់ប្រាក់បីរយណែនក្នុងបាតដៃ

កុមារ, លុះឪបុក្រសោបបុត្រយ៉ាងស្និទ្ធស្នាលហើយ នាងឈរមើលកូនដែលដើរចេញទៅ ជាមួយពួកស្រីបាវព្រាវតាមឋានៈរបស់នាងជាអ្នកមានទ្រព្យនោះ ។

លុះព្រឹកឡើង កុមារបានជួបនឹងមនុស្សម្នាក់ដឹកផ្លែតាមផ្លូវ ក៏សួរថា "លោកពូ! តើសុខចិត្តលក់ផ្លែនេះឲ្យខ្ញុំឬទេ? ខ្ញុំមានចិត្តស្រឡាញ់ផ្លែនេះណាស់" ។ បុរសដឹកផ្លែតបថា "លក់ បើក្មួយចង់ជាវ ដំឡៃរៀលមួយរយណែន" ។ កុមារគ្មានគិតថា "ផ្លែសំគមនេះថ្លៃលើសប្រមាណ" ដូច្នោះទេ បានប្រគល់ប្រាក់គ្រប់ចំនួន គ្មានចេញស្ដីអ្វីមួយម៉ាត់សោះ ហើយបង្គាប់បាវម្នាក់ឲ្យយកផ្លែនោះមកប្រគល់ឲ្យមាតា ។ រីឯមាតាឃើញផ្លែដំបូងកាំងស្មារតី ប៉ុន្តែដល់គិតឃើញថា "ប្រហែលជាមិត្តភក្ដិរបស់ប្ដីនាងបានជួយទិញជូនផង" នាងក៏ខំយកចិត្តទុកដាក់ចិញ្ចឹមផ្លែនេះយ៉ាងម៉ត់ចត់ជាទីបំផុត ។

ថ្ងៃក្រោយមកទៀត លុះបរិភោគបាយរួច កុមារដើរលេងម្នាក់ឯងតាមផ្លូវ បានជួបនឹងមនុស្សម្នាក់ដែលមានកូនឆ្មាតូចមួយ ក៏សួរថា "នាយលក់ឆ្មានុះឬទេ? ។ គេឆ្លើយថា "ខ្ញុំចង់លក់ណាស់ ខ្ញុំលក់ថ្លៃមួយរយណែនប្រាក់" ។ កុមារក៏ទិញដូចកាលពីមុន រួចបញ្ជូនឆ្មានោះមកឲ្យម្ដាយឯផ្ទះ ។ នារីនេះតែងនឹកស្មានថា "បុត្រទិញជូននេះ ដោយមានមិត្តរបស់ស្វាមីនាងជួយមើលការខុសត្រូវផង" ហើយនាងក៏បានថែរក្សាឆ្មានោះដោយយកចិត្តទុកដាក់ដូចផ្លែដែរ ។

នៅចុងក្រោយបង្អស់ ក្នុងថ្ងៃមួយនោះ មួងនេះគឺសត្វក្របីព្រៃដែលកុមារបានជួបប្រទះក៏សួរដូចមុន គេឆ្លើយក៏ដូចមុនថា "ថ្ងៃមួយរយណែន" ៗ កុមារក៏ទិញបញ្ជូនក្របីព្រៃមកផ្ទះដូចមុន ៗ ឯមាតាក៏ខំបីបាច់រក្សាក្របីព្រៃដូចសត្វទាំងពីរមុននោះទៀត ៗ

ឯខ្លែងឹងធ្លាជាសត្វស្រុក នាងបានយកមកទុកក្នុងផ្ទះ ដោយគ្មានគិតភ័យ ៗ ប៉ុន្តែក្របីជាសត្វព្រៃ នាងមិនហ៊ានទុកជិតផ្ទះទេ នាងទុកក្នុងសួនច្បារ នាងខ្លាចសត្វនេះណាស់ ថ្វីបើវានៅស្ងៀមស៊ីតែស្មៅ ៗ នាងខ្លាចទៅជាស្គមខ្លួន ៗ

ថ្ងៃមួយ មានបព្វជិត (អ្នកបួស) មួយរូបដែលចេះធ្វើគ្រូអាចារ្យយ៉ាងពិសេស ត្រងបីពារពេលព្រឹកលៀងនិមន្តមកបិណ្ឌបាត បានឃើញនាងស្គមដូច្នោះក៏សួរថា: "ញោមសិកាឈឺអ្វី? ឯឈឺនេះមកអំពីហេតុអ្វី?" រូបលោកក៏បានរំដោះគ្រោះថ្នាក់ដោយការសូត្រសីលប្រាំឲ្យនាងទទួលតាម គឺសីលស្តីអំពីទ្រព្យសម្បត្តិ, យសស័ក្តិ, កេរ្តិ៍ឈ្មោះ, សេចក្តីសុខ និងសីលទាំងឡាយដែលមានន័យផ្ទុយអំពីនេះ ៗ ស្ត្រីមេម៉ាយបានបង្គំទូលតបវិញថា: "សូមព្រះករុណាជាប ខ្ញុំព្រះករុណាមិនស្រួលខ្លួននេះ មកអំពីបានឲ្យប្រាក់ចំនួនបីរយណែនទៅកូនប្រុសរបស់ខ្ញុំព្រះករុណា ដើម្បីឲ្យវាទៅរកកេរ្តិ៍មកកំរបស់ខ្លាចខ្ចាតុកវា ហើយឲ្យវាសុំរៀនវិជ្ជាផ្សេងៗ ពីគេ ថ្ងៃមួយនោះវាបញ្ជូនថែមកឲ្យខ្ញុំព្រះករុណា ថ្ងៃមួយទៀត

ធ្លា, ថ្ងៃក្រោយទៀតក្របីព្រៃ ដំថ្លៃសត្វនីមួយៗ មួយរយណែនប្រាក់; ឯផ្ទៃនឹងធ្លាជាសត្វស្រុក ខ្ញុំព្រះករុណាមិនខ្លាចទេ, ប៉ុន្តែក្របីព្រៃជាសត្វកាចសាហាវ ខ្ញុំព្រះករុណាឃើញកាលណា មានចិត្តភិតភ័យញ័រអស់ទាំងខ្លួនប្រាណ, មួយទៀតដោយសារតែកូនខ្ញុំស្រឡាញ់សត្វទាំងបីនេះពេកទៅ ខ្ញុំព្រះករុណាក៏ធ្វើព្រងើយមិនកើត" ។

ក្នុងពេលនោះ លោកសង្ឃបានទូន្មាននាងឲ្យលែងក្របីព្រៃ តាមធម៌ព្រះពុទ្ធ ។ នាងក៏បានលែងសត្វនេះឲ្យទៅក្នុងព្រៃ ហើយបានទាំងឲ្យចំណីដល់ក្របីព្រៃនេះស៊ីក្នុងពាងមួយធំផង ។

ឯក្របីព្រៃបានបណ្ដោយឲ្យនាងធ្វើតាមអំពើចិត្ត, លុះទៅដល់ក្នុងព្រៃជ្រៅវេលាណាក៏គិតថា: "កូនមហាសេដ្ឋីបានទិញអញមកថ្លៃមួយរយណែន, តាំងអំពីអញទៅនៅជាមួយនឹងគេៗបីបាច់ចិញ្ចឹមអញយ៉ាងម៉ត់ចត់; មួយទៀត ដោយសារតែម្ដាយគេបានជាអញរួចខ្លួនជាអ្នកជា ហេតុដូច្នេះត្រូវអញរកមធ្យោបាយណាមួយ ដើម្បីសងគុណគេ ព្រោះគេបានធ្វើល្អនឹងអញនេះ" ។

លុះគិតយូរបន្តិចទៅ ក្របីព្រៃយកមាត់ខាំចិញ្ចៀនពេជ្រមួយវង់នៅជិតគល់ឈើ ដែលទេវតាបានធ្វើឲ្យបាត់កណ្ដាលព្រៃ រួចនាំយកមកឲ្យបុរសជាចៅហ្វាយ[១] ហើយនិយាយថា: "លោកចូរយកចិញ្ចៀននេះ

---

១ កុមារដែលទិញក្របីព្រៃអំពីមុន ។

ទៅចុះ ខ្ញុំជូនលោក, ឯចិញ្ចៀននេះមិនដូចអស់ចិញ្ចៀនផងទាំងពួងទេ គឺចិញ្ចៀននេះមានឥទ្ធិរិទ្ធិយ៉ាងពូកែណាស់ គ្រាន់តែយកទៅត្រូតនឹងរបស់អ្វីមួយ អាចកើតរបស់ផ្សេងៗតាមបំណងដល់ម្ចាស់ចិញ្ចៀននេះបាន ប៉ុន្តែហាមម្ចាស់ពាក់ចិញ្ចៀននេះនៅម្រាមដៃទៅចុះ ហើយប្រុងប្រយ័ត្នកុំឲ្យចិញ្ចៀននេះទៅអ្នកឯណាសោះ" ។ ថាហើយក្របីព្រៃត្រឡប់ចូលទៅក្នុងព្រៃជ្រៅវិញបាត់ទៅ ។

លុះបានចិញ្ចៀននោះមក បុរសនោះបានពាក់នៅម្រាមដៃបំពេញបំណងរបស់ខ្លួន, រួចមានពាក្យមួយនោះ បានក្លាយឲ្យកើតជាប្រាសាទមួយយ៉ាងល្អឆើតឆាយ ប្រកបដោយដំបូលប្រាំពីរជាន់ នៅចំពីមុខគេហស្ថានរបស់ខ្លួន ។

បុរសបាននាំទាសាទាសីឡើងទៅនៅក្នុងប្រាសាទនោះ, ក្រោយមកមានអ្នកជិតខាងផងទាំងពួង មកជុំកុះករមើលវិចិត្ររចនានៃប្រាសាទនេះ, ក្នុងបណ្ដាពួកអ្នកមើលនោះ មានព្រះមហាក្សត្រិយ៍ និងព្រះរាជបុត្រីព្រះអង្គផង ។ បុរសបានរៀបចំទទួលព្រះមហាក្សត្រិយ៍យ៉ាងឧឡារិក ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យនឹងបុរសម្ចាស់ប្រាសាទជាទីបំផុត រួចទ្រង់លើកបុត្រីឲ្យមកបុរសនោះធ្វើជាអគ្គមហេសី ។

លុះកន្លងអំពីពេលដ៏ក្សេមក្សាន្តនេះបន្តិចមក លោកសង្ឃដែលជាគ្រូអាចារ្យរបស់ម្ដាយបុរសនោះ បានធ្វើឧបាយកលថា មកទេសនា

នៅក្នុងប្រាសាទ ។ ព្រោះលោកចង់ដឹងថា: តើបុរសមានគ្រឿងអ្វីមួយក៏ពូកែដល់ម្ល៉េះ អាចបង្កើតជាប្រាសាទមួយយ៉ាងល្អស្កុកស្តម្ភ្លាមៗយ៉ាងដូច្នេះ ។ ឯលោកសង្ឃនេះជាមនុស្សទុច្ចរិតឃោរឃៅ ស្លៀកពាក់តាមបែបលោកសង្ឃ ដែលគេតែងជួបប្រទះនៅនាលោកនេះ ។

លោកសង្ឃឆ្លៀតរកឱកាសដែលបុរសមិននៅ ដើម្បីចូលមកក្នុងប្រាសាទ ។ លុះបានឱកាសហើយ ក៏ចូលមកនិយាយបញ្ឆោរបញ្ឆោតកិរិយារបស់បុរសអស់កាលជាយូរហើយទើបសួរថា "តើប្ដីនាងស្រឡាញ់នាងមែនទែនឬអ្វី?" ។ នាងឆ្លើយថា "ម្ដេចព្រះតេជព្រះគុណ មានពុទ្ធដីកាយ៉ាងដូច្នោះ? ប្ដីខ្ញុំព្រះករុណា គ្រាន់តែជាកូនមហាសេដ្ឋីប៉ុណ្ណោះទេ ឯខ្ញុំព្រះករុណាជាបុត្រីស្ដេចផែនដី, ហេតុដូច្នេះ ការណ៍ដែលខ្ញុំព្រះករុណាទទួលធ្វើជាប្រពន្ធនេះ បង្ហាញឲ្យឃើញថា ខ្ញុំព្រះករុណាស្រឡាញ់គេយ៉ាងពេញចិត្តជាទីបំផុត បំណែកខាងគេជាប្ដីនោះ គេក៏ស្រឡាញ់ខ្ញុំព្រះករុណា យ៉ាងខ្លាំងដូចគ្នាដែរ" ។

លោកសង្ឃឆ្លើយថា "បើប្ដីញោមស្រឡាញ់ញោមជាទីបំផុតយ៉ាងដូច្នេះ តើគេមានដែលឲ្យញោមពាក់ចិញ្ចៀនមួយណាឬទេ?" ។ នាងឆ្លើយវិញថា "ទេគេមិនដែលឲ្យខ្ញុំព្រះករុណាពាក់ទេ ប៉ុន្តែខ្ញុំព្រះករុណាមិនដែលសុំពាក់ផង" ។ លោកសង្ឃលុះបានឮដូច្នោះហើយ ក៏អស់

សង្ស័យ ហើយថយខ្លួនទៅវិញភ្លាម ៗ ក្នុងកាលណោះគ្រាប់អាសិរពិសចាប់ពន្លកដុះហើយ ៗ ព្រះភិក្ខុសង្ឃក៏ដឹងចិត្តស្ត្រីជាស្រេច ៗ

មួយថ្ងៃឬពីរថ្ងៃក្រោយពេលដែលពិភាក្សានេះ នារីបានសុំស្វាមីពាក់ចិញ្ចៀនដែលមានត្បូងពេជ្រទាំងគ្រាប់ចាំងចិញ្ចែងនុះមុខ ៗ ឯស្វាមីដោយស្រឡាញ់កិរិយាពេក ហើយដោយមិនចង់ឲ្យនាងអាក់ចិត្តកន្លែងណា ក៏បានហូតចិញ្ចៀនពីម្រាមដៃ ហើយយកទៅស៊កនៅដៃនាងហើយផ្ដែផ្ដាំហាមផ្ដាច់ កុំឲ្យទៅអ្នកឯណាមួយឲ្យសោះ គឺឲ្យពាក់ជាប់នឹងដៃជានិច្ច ៗ

ថ្ងៃមួយនោះ បុរសមិននៅ លោកសង្ឃចូលមកក្នុងប្រាសាទម្ដងទៀត ហើយនិយាយបញ្ចុះបញ្ចូលនាងសព្វគ្រប់ប្រការ ៗ ឯនាងក៏រីករាយក្នុងចិត្តហើយនិយាយថា: “ទានប្រាស! នេះចិញ្ចៀនដែលព្រះតេជព្រះគុណមានព្រះពុទ្ធដីកាពីថ្ងៃមុននោះ ខ្ញុំព្រះករុណាយកមកពាក់នៅម្រាមដៃ” ៗ ភិក្ខុនោះសួរដោយត្រេកអរថា: “ឯណាចិញ្ចៀននោះ?” ៗ នាងក៏បង្ហាញចិញ្ចៀនដ៏មានត្បូងក្រូវន្ទាលឲ្យភិក្ខុនោះមើល ៗ

លោកសង្ឃក៏អង្វរនាងឲ្យដកចិញ្ចៀនដ៏វិសេសនោះ ពីម្រាមដៃយកមកមើលឲ្យជាក់មួយស្របក់ ព្រោះមានគេតែងសរសើរចិញ្ចៀននេះគ្រប់គ្នាក្នុងព្រះរាជអាណាចក្រ ហើយព្រោះគ្មានស្ត្រីឯណាមួយមានពាក់ក្នុងលោកនេះ ៗ (មាន៩)

# រឿងសាមកុក

## កណ្ឌទី ៨

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ចាប់តាំងពីលីឈុយ, គុយគី, តៀវបេនឹងហួនតៀវ ធ្វើសំបុត្រទៅជំរាបអងអ៊ុន
រហូតដល់តៀវឃីលើកទាហានទៅសម្លាប់ហោកោជាអាពុកហោធោ ។

ឯលីឈុយ, គុយគី, តៀវបេនឹងហួនតៀវជាសេនាតាំងតុះ ដែលរត់ទៅនៅស្រុកសៀងសៃនោះ ប្រឹក្សាគ្នាធ្វើជាសំបុត្របាត់បំរើឲ្យកាន់ចូលមកជំរាបអងអ៊ុន សេចក្ដីថា "យើងខ្ញុំបានទៅនៅជាពួកបក្សតាំងតុះនោះ ដោយសេចក្ដីទាល់គំនិត មិនបានគិតយកជាទីពឹងអស់ហើយទេ ទោសយើងទាំង ៤ នាក់ដែលយើងធ្វើទៅហើយសូមលោកអភ័យចុះ ឥឡូវនេះ យើងខ្ញុំសូមសំអាងខ្លួននឹងចូលមកនៅធ្វើរាជការនឹងលោកតទៅ" ។

អង់អ៊ីនទទួលសំបុត្រមើលដឹងសេចក្ដីហើយនិយាយនឹងបំរើថា ដែលតាំងតុះធ្វើការអាក្រក់ពីព្រោះតែលីឈុយ គុយគី តៀវបេ នឹងហួនតៀវ ឥឡូវនេះ បើមានព្រះត្រាស់ឲ្យលើកទោសមនុស្សទាំងអស់បាន យើងត្រូវព្រមតាម តែឯលីឈុយ គុយគី តៀវបេ នឹងហួនតៀវ នោះយើងនឹងទៅសុំអនុញ្ញាតយកខ្លួនមកសម្លាប់ចេញឲ្យបាន" ។ បំរើកាន់សំបុត្រក៏លាត្រឡប់ទៅប្រាប់លីឈុយ គុយគី តៀវបេ នឹងហួនតៀវតាមពាក្យនោះ ។ ឈ្មោះទាំង ៤ នាក់ប្រឹក្សាគ្នាថា ដែលយើងនឹងទៅចុះចូលនៅនឹងអង់អ៊ីននោះ មិនសម្រេចតាមប្រាថ្នាទេ បើដូច្នេះត្រូវតែយើងដោះខ្លួនរៀងខ្លួនឲ្យរួចទៅចុះ ។

ឯកាសៀងជាទីប្រឹក្សាឆ្លើយឡើងថា យើងនឹងគិតតែរត់ចៀសចេញទៅនោះក៏មិនផុត សុំឲ្យគិតបញ្ចុះបញ្ចូលអ្នកស្រុកសៀងសៃបានជាពួកហើយ លើកកងទ័ពទៅវាយយកស្រុកតៀងហានវិញ បើបានស្រុកនោះហើយត្រូវតែចាប់សម្លាប់អង់អ៊ីនចេញ លោកទាំងបួននាក់នឹងបានធ្វើរាជការក្នុងស្រុកក្រុងតទៅ បើគិតដូច្នេះហើយមិនសម្រេចដូចគំនិតទេ សុំនាំគ្នារត់ចៀសចេញទៅចុះ ។ លីឈុយ គុយគី តៀវបេ នឹងហួនតៀវស្ដាប់ហើយឃើញត្រូវផង ក៏ទៅចាត់ចែងរើសទាហានដែលមានសតិបញ្ញាឲ្យចេញទៅបញ្ចុះបញ្ចូលពួកអ្នកស្រុកសៀងសៃថា ឥឡូវនេះអង់អ៊ីនបានជាធំក្នុងស្រុកក្រុងហើយ ប៉ងនឹងលើកទាហានមកសម្លាប់អ្នកស្រុកនេះ ដែល

ជាអ្នកគ្មានកំហុសឲ្យអស់ ដោយឃើញកំហុសដូច្នេះ ទើបលីឈុយឲ្យយើងមកបញ្ចុះបញ្ចូលអ្នកស្រុកនឹងក្រៅស្រុកទាំងអស់គ្នា បើអ្នកឯណាស្រឡាញ់ជីវិតខ្លាចអង់អ៊ុននឹងសម្លាប់ ត្រូវប្រញាប់ឲ្យចូលមកនឹងយើង ទើបរួចភ័យអន្តរាយ ។ ឯអ្នកស្រុកសៀងសែកាលបានដឹងសេចក្តីដូច្នោះ ក៏ភ័យបារម្ភខ្លាចស្លាប់ ទើបនាំគ្នាប្រញាប់ចុះចូលមកជាពួកលីឈុយ គុយគី គៀវបេងនឹងហ៊ួនគៀវលើកទៅជាប្អូនកង លុះទៅដល់កណ្តាលផ្លូវប្រទះនឹងងីវហ៊ូជាកូនប្រសាតាំងគុ: លើកទាហាន ៩០០ នឹងចូលទៅសង្គ្រោះអង់អ៊ុន ។ នាយទ័ពទាំង ៤ កងចាត់ឲ្យងីវហ៊ូជាមេទ័ពស្រួច ហើយលើកទៅជិតដល់ស្រុកគៀងហាន់ ។

ឯអង់អ៊ុនកាលបើបានដឹងដំណឹង ជាមានកងទ័ពលើកទៅជិតទីក្រុង ហើយប្រឹក្សានឹងលីប៉ោថា ដែលលីឈុយ គុយគី លើកទ័ពមកគ្រានេះ តើយើងនឹងគិតការដូចម្តេច? ។ លីប៉ោតបថា "លីឈុយ គុយគី លើកមកនេះ លោកកុំវិតក្កឡើយ ការនេះជាធុរៈលើខ្ញុំ" ហើយឲ្យលីសុកលើកទាហានចេញទៅតទល់ ។ កាលលីសុកលើកទ័ពទៅនោះ បានជួបប្រទះនឹងទ័ពងីវហ៊ូ បានតយុទ្ធគ្នាជាម៉ាមួន ។ ងីវហ៊ូឃើញកំឡាំងនឹងតទល់ពុំបាន ក៏នាំទាហានថយទ័ពត្រឡប់ទៅក្រោយវិញ ។ លីសុកក៏មានចិត្តកំរើកឲ្យទាហានទៅនៅប្រជុំគ្នា មិនបានបំបែកឲ្យត្រូវត្រាតាមរបៀបទ័ព ។ ងីវហ៊ូឃើញលីសុកប្រហែសការ, ដល់ពេលយប់យាមពីរ

ក៏លើកទាហានវាយបំពានទ័ពលីសុក សម្លាប់ទាហានបានជាច្រើន ៗ លីសុកក៏រត់រួចទៅបាន ទើបនាំយកសេចក្ដីដែលបានធ្វើសង្គ្រាមនោះ ប្ដឹងចូលទៅដល់លីប៉ោ ៗ ដឹងហើយខឹងណាស់ ក៏បង្គាប់ឲ្យយកខ្លួនលីសុក ចូលទៅកាត់ក្បាលដោតនៅមាត់ទ្វារស្រុក ៗ

លុះវេលាព្រឹកឡើង លីប៉ោលើកទាហានទៅតយុទ្ធនឹងនីវហ៊ូ ៗ បែកទ័ពត្រឡប់រត់រួចទៅ ៗ នីវហ៊ូក៏ប្រឹក្សានឹងអៅសុកយ៉ីថា លីប៉ោនោះមានកំឡាំងខ្លាំងពូកែណាស់ យើងតស៊ូនឹងគេពុំបានទេ បើដូច្នេះត្រូវតែគិតរត់ទៅទៀត ៗ អៅសុកយ៉ីបានស្ដាប់ហើយក៏យល់ព្រមផង, ដល់ពេលអធ្រាត្រស្ងាត់ នីវហ៊ូរៀបប្រមូលយកទ្រព្យរបស់ផងខ្លួនដែលមានដំឡៃហើយនាំអៅសុកយ៉ីនឹងទាហានដែលស្និទ្ធ ៤ - ៥ នាក់រត់ទៅដល់មាត់ស្ទឹង ៗ អៅសុកយ៉ីប្រែចិត្តក្បត់សម្លាប់នីវហ៊ូស្លាប់ ហើយយកទ្រព្យរបស់ទាំងអស់នោះ នាំពួកទាហាន ៤ - ៥ នាក់នឹងក្បាលនីវហ៊ូទៅឲ្យលីប៉ោក្នុងក្រុងតៀងហាន់ ៗ លីប៉ោឃើញដូច្នោះក៏នឹកសង្ស័យនឹងអៅសុកយ៉ីណាស់ ក៏លបសួរមនុស្សដែលទៅជាមួយថា កើតហេតុទាស់ទែងគ្នាដូចម្ដេចបានជាអៅសុកយ៉ីសម្លាប់នីវហ៊ូ ៗ មនុស្សពួកនោះឆ្លើយឲ្យការតាមដំណើរសព្វគ្រប់ ៗ

លីប៉ោបានស្ដាប់ហើយខឹងណាស់ថា "អៅសុកយ៉ីជាមនុស្សលោក មិនមានសេចក្ដីសុចរិតពិតត្រង់ នឹងចិញ្ចឹមទុកជាគ្នាក៏ពុំបាន" ទើបបង្គាប់

ឲ្យទាហានចាប់អៅសុកយើងនាំទៅសម្លាប់ ។ ឯលីប៉ោចាត់ចែងទាហាន កងទ័ពលើកទៅប្រទះនឹងទ័ពលីឈុយ គុយគី គៀវចេងនិងហួនគៀវ ក៏បរសេះនាំពលទាហានចូលច្បាំងគ្នា ។ កងទ័ពលីឈុយ គុយគី គៀវចេងនិងហួនគៀវមិនទាន់បានត្រៀមខ្លួនក៏បែកខ្ចាត់ខ្ចាយអស់ទៅ រត់តាមផ្លូវប្រហែល ៥០០ សិន (២០ គីឡូម៉ែត្រ) ដល់ភ្នំមួយក៏បង្គាប់ឲ្យកបន្ទាយយ៉ាងមាំមួននៅទីនោះ ។ លីឈុយទើបប្រឹក្សានិងគុយគី គៀវចេងនិងហួនគៀវថា " លីប៉ោនោះមានថ្វីដៃខ្លាំងពូកែណាស់ តែជាអ្នកមិនមានដំរេះប្រាជ្ញាធ្លាត យើងនឹងគិតឧបាយឲ្យគុយគីយុំទាហានទៅចាំស្កាត់ផ្លូវដែលនឹងចូលទៅកងស្រុក បើកាលណាឃើញទ័ពលីប៉ោយើងត្រូវតយុទ្ធជាកលបញ្ឆោត បើបានឮសំឡេងគងឃ្មោះវេលាណាឲ្យបរពលចូលច្បាំង បើឮសំឡេងស្គរទៀតឲ្យថយទាហានទៅក្រោយ ឯគៀវចេង ហួនគៀវឲ្យលើកទាហានបំបែកគ្នាទៅវាយទំលាយស្រុកគៀងហាន់ជា ២ ផ្លូវ បើធ្វើដូច្នេះឃើញថាលីប៉ោនោះនឹងច្បាំងតទល់មុខក្រោយមិនទាន់ការនឹងខូចអស្សារដល់ពួកយើងជាប្រាកដ ។ គុយគី គៀវចេងនិងហួនគៀវយល់ឃើញត្រូវ ក៏លើកទាហានចេញទៅតាមពាក្យលីឈុយ ។

គ្រានោះ លីប៉ោលើកទ័ពទៅដល់ប្រហាកប្រែកភ្នំប្រទះនឹងកងទ័ពលីឈុយចូលប្រយុទ្ធគ្នាជាកោលាហល ។ លីឈុយឲ្យវាយស្គរថយទ័ពត្រឡប់ឡើងទៅលើភ្នំ, លីប៉ោបង្ខំដេញចូលទៅ ស្រាប់តែទាហាន

លីឈុយបាញ់ធ្នូហោលដុំថ្មទម្លាក់ចុះមកដូចគ្រាប់ភ្លៀង, លីប៉ោក៏ឲ្យទាហានថយមកក្រោយវិញ ។

ឯទ័ពគុយគីដែលនៅពីក្រោយបានឃើញដូច្នោះ ឲ្យវាយគងឃ្មោះលើកទាហានបន្ទ្រុះចូលទៅទៀត, លីប៉ោឲ្យបែមុខទ័ពត្រឡប់មកតទល់, គុយគីឲ្យវាយស្គរពីលើភ្នំហើយនាំទាហានចុះមកវិញ ដេញទាហានឲ្យវាយពីខាងក្រោយបណ្ដាយទៅ, ទ័ពលីប៉ោក៏នៅជាកណ្ដាល ។ តាំងពីកងទ័ពលីឈុយគុយគីខ្ទប់ទ័ពលីប៉ោនៅទីនោះ ចំនួន ៣ យប់ ៣ ថ្ងៃ ។ លីប៉ោក៏បែរតទល់ទាំងមុខនឹងក្រោយវិលនៅជុំវិញមិនដឹងជានឹងវាយទំលុះទៅខាងណាបាន ទទួលមានបំរើសេះបេះជ្រៀតជ្រែកដែងចូលទៅប្រាប់លីប៉ោថា ឥឡូវមានកងទ័ពគៀវបេនឹងហ្វូនគៀវលើកចូលទៅច្បាំងទំលាយយកទីក្រុងគៀងហាន់ ហើយសុំឲ្យលីប៉ោលើកទ័ពទៅជួយជាប្រញាប់ ។ លីប៉ោគិតនឹងទៅជួយខាងស្រុកក្រុងទើបឃុំនាំទាហានសេះបំពានវាយទំលាយចេញទៅបាន ។ ឯលីឈុយ គុយគីលើកទ័ពតាមទៅទៀត, លីប៉ោមិនមានញញើតដៃសោះ បែរមកតទល់ទ័ពទាំងអស់ពីក្រោយហើយស្រុតទៅមុខ លុះទៅដល់ជិតស្រុកក្រុងឃើញទាហានគៀវបេនឹងហ្វូនគៀវឡោមព័ទ្ធ, ឯលីប៉ោនោះមិញចូលទៅប្រយុទ្ធឥតរួញរា តែថាទាហានលីប៉ោវិនាសស្លាប់ជាច្រើនណាស់ ខ្វះរត់ចូលទៅនៅខាងកងទ័ពគៀវបេ ហ្វូនគៀវជាច្រើន លីប៉ោឃើញដូច្នោះនឹកតូចចិត្តណាស់ទើបនាំទាហានដែលសល់នៅវិលវល់ក្នុងចំណោមទ័ពគ្រប់ ២ - ៣ ថ្ងៃ ។

ឯលីបង់ អង់ហង់ទាំង ២ នាក់ជាបក្សពួកតាំងគុ:នៅក្នុងស្រុកគៀង-ហាន់ កំណាន់ចិត្តគិតស្អប់អង់អ៊ុនណាស់ គិតៗបាយជាកលសឹកលើកទាហានរបស់ខ្លួនទៅពួនបើកមាត់ទ្វារទាំង ៤ ទិស ទទួលយកកងទ័ពលីឈុយ គុយគី គៀវបេទឹងហ្លួនគៀវឲ្យចូលទៅបាន ។ លីប៉ោកំស៊ុះបំពានលឿនទៅមុខតាំងតែចាក់កាប់សម្លាប់កងទ័ពលីឈុយ គុយគីស្លាប់ពិការជាច្រើនណាស់ ហើយត្រឡប់លើកទាហានរបស់ខ្លួនប្រហែល ១០០ ប្លាយពារទំលាយចូលទៅដល់ទ្វារព្រះរាជវាំង ជួបនឹងអង់អ៊ុនហើយនិយាយថា សង្គ្រាមម្តងនេះធំលើសលប់ពេកណាស់ បើយើងនឹងនៅតទល់នោះ ឃើញលើសហួសកំឡាំង សូមលោកស្រូតប្រញាប់ឡើងសេះរត់ឲ្យរួចតែខ្លួនទៅសិនចុះ ក្រោយពីនេះសុំគិតការតទៅ ។

អង់អ៊ុនតបថា ពីដើមខ្ញុំនឹងអ្នកគិតគ្នានឹងទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខក្សេមក្សាន្ត, សេចក្តីដែលគិតនោះបានសមដូចប្រាថ្នាហើយ តែឥឡូវកើតហេតុឡើងទៀតព្រោះពួកតាំងគុ: ដែលយើងនឹងលះបង់ចោលស្រុកក្រុងរត់យកតែខ្លួននោះមិនគួរសោះ ទោះនឹងស្លាប់ក៏គួរយកសេចក្តីត្រូវទុកជាខាងមុខ ចំណែកលោកបើនឹងទៅក៏ទៅចុះ តែត្រូវជួយយកសេចក្តីទៅប្រមាណប្រាប់ដល់បណ្តាចៅហ្វាយខែត្រខាងក្រៅថា យើងសូមគំនាប់មក ដ្បិតសម័យនេះកើតហេតុក្នុងស្រុកក្រុងជាចលាចល ឲ្យចៅហ្វាយខែត្រទាំងអស់យកចិត្តទុកដាក់ជួយទំនុកបំរុងផែនដីលើកកងទ័ព

មកជួយកំចាត់សត្រូវកេជសម្បត្តិឲ្យអស់ចេញ ។ លីប៉ោបានព្រួដូចោះ
ក៏និយាយបញ្ចុះបញ្ចូលបបួលអង់អ៊ុនជាច្រើនដង អង់អ៊ុនក៏មិនព្រមទៅ
ទទួលក្រៀកឃើញពន្ទីភ្លើងឆេះឡើងគ្រប់តំបន់ដែលសត្រូវចូលទៅដុត
លីប៉ោក័យរន្ធត់រត់ចោលអស់គ្រួសារឡើងជិះសេះនាំសេនាទាហានប្រ-
ហែល ១០០ ព្យាយចេញទៅដល់អួនសុតនៅស្រុកឡាំយ៉ុង, ឯអង់អ៊ុន
ក៏ចូលទៅក្នុងព្រះរាជវាំង ។

ខណៈនោះ លីឈុយ គុយគី គៀវបេ ហួនគៀវ ដែលហែកទ្វារ
ស្រុកចូលទៅក្នុងទីក្រុងនោះ កាប់សម្លាប់នាហ៊ុនមុខមន្ត្រីនៅអាណា
ប្រជានុរាស្ត្របួសពិការស្លាប់ជាច្រើន ហើយលើកទាហានចូលទៅក្នុង
ព្រះរាជវាំង ។ ខន្ទីទាំងពួងឃើញដូច្នោះស្ទុះចូលទៅអញ្ជើញស្ដេចព្រះចៅ
ហៀនតេនឹងអង់អ៊ុន ឡើងទៅគង់លើដំណាក់ថ្នាក់លើ ។ លីឈុយ
គុយគី នឹងសេនាទាហានទាំងពួង ក៏នូនគំនាប់ថ្វាយបង្គំពីខាងក្រោម
ទៅ ព្រះចៅហៀនតេទតព្រះនេត្រមកឃើញហើយ មានព្រះតម្រាស់
ត្រាស់សួរថា ដែលខ្ញុំអង្គាបតុំខាងព្រះចេស្ដា លើកសេនាទាហាន
ពានព្រះរាជវាំងចូលមកនេះ នឹងប្រាថ្នារបស់អ្វី? ។ លីឈុយ គុយ
គីក្រាបទូលថា ទូលព្រះបង្គំទាំងឡាយ ធ្វើការទាំងនេះនឹងបានគិតក្បត់
ព្រះអង្គក៏ទេ កាលពីដើមតាំងតុងដាមហាចបរាជបានទំនុកបំរុងផែនដី
ថ្វាយព្រះករុណាជាសុខរៀងមក តែអង់អ៊ុនទឹងលីប៉ោគប់គិតគ្នាសម្លាប់

មហា•បពជចេញដោយអំណាចចិត្ត ទូលព្រះបង្គំជាខ្ញុំឈឺចិត្តណាស់ ចូលមកនេះប្រាថ្នានឹងសម្លាប់អង់អ៊ុនចេញឲ្យអស់កំហឹង បើព្រះអង្គទ្រង់ព្រះមេត្តាប្រគល់ខ្ញុំអង់អ៊ុនឲ្យហើយ ទូលព្រះបង្គំជាខ្ញុំនឹងនាំទាហានចេញទៅវិញ ។

អង់អ៊ុនបានស្តាប់ក៏ក្រាបទូលព្រះចៅហ្វៀនតេថា "ទូលព្រះបង្គំជាខ្ញុំមានសេចក្តីពិតត្រង់នឹងផែនដីជាប្រាកដ ទើបសម្លាប់តាំងតុះដែលក្បត់នឹងព្រះករុណានោះចេញ ឥឡូវលីឈុយ គុយគីចង់សម្លាប់ទូលព្រះបង្គំជាខ្ញុំវិញ បើទូលព្រះបង្គំជាខ្ញុំនៅស្រឡាញ់ជីវិតគិតតែជកពួនដូច្នេះ នឹងកើតអន្តរាយក្នុងព្រះរាជបានច្រើនឡើងទៀត ហេតុនេះសូមយកជីវិតទៅឲ្យលីឈុយ - គុយគីសម្លាប់ចេញចុះ បំពោះជាទីតបស្នងគុណព្រះតេជព្រះគុណព្រះករុណា" ថាហើយក៏លោតចុះទៅតាមផ្លូវដើរដំណើរព្រះតំណាក់ស្រែកថា "ខ្ញុំអញនៅឯណោះ ឯងនឹងចង់ធ្វើប្រការម្តេចក៏ធ្វើឲ្យស្រេចទៅចុះ" ។ លីឈុយ គុយគីឆ្លើយថា មហាឧបរាជមានទោសកំហុសពីព្រោះអ្វី · បានជាឯងគប់គិតបួលកំទិតនឹងលីថោសម្លាប់ចេញ ។ អង់អ៊ុនតបថា តាំងតុះរាជាសត្រូវរាជសម្បត្តិ ធ្វើការអាក្រក់ដល់រាជសម្បត្តិច្រើនណាស់ បានជាអញសម្លាប់វាចេញ នាហ្មឺននឹងបណ្តាស្រុកទាំងអស់មានសេចក្តីត្រេកអរលើសលប់ ហេតុម្តេចឯងមានចិត្តគំនុំគុំគួនជាមួយនឹងពួកអាក្បត់នោះ ។ (មានត)

ភាគទី ២

## សម័យនគរធំ

# អ្នកឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

តែប្រាសាទវិស្ណុលោកនេះ តាមសំដីសាមញ្ញក្នុងបច្ចុប្បន្នហៅថា នគរវត្ត, នៅខាងត្បូងក្រុងប្រមាណជាង ១ គីឡូម៉ែត្រ ទ្រង់ឧទ្ទិសថ្វាយព្រះវិស្ណុ (នារាយណ៍) ដែលជាព្រះ ១ អង្គក្នុង ៣ អង្គ ក្នុងលទ្ធិសៃយ ៗ មិនត្រឹមតែឧទ្ទិសថ្វាយទេ ទ្រង់បានតាំងសាងព្រះរូបព្រះវិស្ណុនោះយ៉ាងធំដំ ហើយដោយថ្ម ប្រតិស្ឋាននៅក្នុងប្រាសាទកណ្តាល នាថ្នាក់ទី ៣ សម្រាប់ធ្វើសក្ការបូជា[១] ៗ

ក្រៅពីរូបព្រះវិស្ណុ ទ្រង់បានឲ្យឆ្លាក់រូបភាពព្រះនារាយណ៍ (នារាយណ៍អវតារ) បែងភាគ ក្នុងគ្រាផ្សេងៗ នៅនាព្រះរបៀងទី ១ ទី ២ មានរឿងរាមាយណៈ (រាមកេរ្តិ៍), មហាភារតយុទ្ធ, ហរិវង្ស ជាដើម ទឹងទ្រង់ឆ្លាក់រូបភាពកងទ័ពខ្មែរ ទុកនៅព្រះរបៀងទី ១ ភាគខាងត្បូង ប៉ែកខាងលិច ដំណាលកាលព្រះអង្គទៅធ្វើព្រះរាជសង្គ្រាម

---

១ ក្រោយមក កាលព្រះពុទ្ធសាសនាលទ្ធិលង្កាផ្សាយមក គេយករូបព្រះវិស្ណុនោះចេញហើយគេយកផែនថ្មធំៗ ទៅសន្ធប់មាត់ទ្វារទាំង ៤ ហើយឆ្លាក់ជាព្រះពុទ្ធរូបឈរធំៗ បែរព្រះភ័ក្ត្រឈមទៅឥខទិស ទាំង ៤ ។

នៅក្រុងវិជ័យ ទុកជាប្រវត្តិសាស្ត្ររបស់ព្រះអង្គ នៅខាងក្រោយកំពង់ទឹកមានព្រះបរមរូបរបស់ព្រះអង្គ ប្រកបរឿងនោះផង ។ ក្នុងរូបភាពកំពង់ទឹកនោះ គេសង្កេតឃើញមានជនជាតិសៀម បានស្ម័គ្រធ្វើទាហានក្នុងកងទ័ពស្រុកនោះ ដោយមានចារឹកជាអក្សរថា "សៀមកុក" នៅទីនោះជាសំគាល់ផង ។

ក្រោយដែលសាងប្រាសាទវិស្ណុស្រេចហើយ ព្រះបាទសូរ្យវរ្ម័នទ្រង់បានកែប្រែលក្ខណៈរូបទង់ជាតិចេញទៅខ្លះ គឺត្រង់កណ្តាលផ្ទៃដែលធ្លាប់ប្រើពណ៌សសុទ្ធពីដើមមកនោះ ទ្រង់ឲ្យដាក់រូបប្រាសាទកំពូល ៣ ជំនួសត្រង់នោះ ជាគ្រឿងសំដែងកិត្តិយសជាតិខ្មែរ ដែលមានប្រាសាទសិលាល្អបំផុត ធំធេងជាបំផុត សឹងគ្មានប្រទេសណាក្នុងពិភពលោកនេះមានដូចទង់រូបប្រាសាទបែបនោះ បានប្រើរហូតមកដល់បច្ចុប្បន្ន ។

ព្រះបាទសូរ្យវរ្ម័នអង្គនេះហើយដែលក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាហៅថា ព្រះបាទព្រះបទុមសុរិយវង្ស ទ្រង់ជាក្សត្រិយ៍ ១ អង្គដែលមានអភិនិហារធំព្រះតេជានុភាពជាអស្ចារ្យ យ៉ាងដែលហៅថាមានបុណ្យកក្រើកផែនដី ជាទីកោតញញើតរបស់នានាប្រទេសដែលនៅជិតខាង (តែមិនមែនមានព្រះនេត្រទិព្វដូចមានពោលក្នុងព្រះរាជ-ពង្សាវតារក្រុងកម្ពុជានោះទេ) ។ ព្រះអង្គមានព្រះកិត្តិយសជាមហារាជា-ធិរាជ ១ អង្គ ក្នុងប្រវត្តិសាស្ត្រ ។

កាលទ្រង់សោយទិវង្គតហើយ រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា ព្រះបាទបរមវិស្ណុលោក តាមហេតុដែលទ្រង់រាប់អានលទ្ធិវិស្ណុវៈ ។

## ព្រះបាទជយវរ្ម័នទី ៧

### ព.ស. ១៧២៤ - ១៧៤៨ គ.ស. ១១៨១ - ១២០៥

### កាលព្រះបាទធរណេន្ទ្រវរ្ម័នទី ២ សោយទិវង្គតហើយ

ព្រះជយវរ្ម័ន ជាព្រះរាជឱរសព្រះបាទធរណេន្ទ្រវរ្ម័នទី ២ នឹងព្រះនាងចូឌាមណីអគ្គមហេសី ហើយត្រូវជាព្រះអនុជរួមព្រះរាជអយ្យិកានឹងព្រះបាទសូរ្យវរ្ម័នទី ២. ទ្រង់មានព្រះអគ្គទេពីតាំងពីនៅកុមារ មុនសោយរាជសម្បត្តិ ព្រះនាមជយរាជទេវី ជាព្រះធីតានៃព្រះរុទ្រវរ្ម័ននឹងព្រះនាងរាជេន្ទ្រលក្ស្មី ទ្រង់មានព្រះរាជឱរស ១ អង្គព្រះនាម លក្ខេទយេស ឬ ឥន្ទ្រវរ្ម័ន ។

និយាយតាមច្បាប់រាជសន្តតិវង្ស រាជសម្បត្តិក្នុងពេលនោះត្រូវបានទៅព្រះជយវរ្ម័ន ដ៏ជាព្រះរាជឱរស ព្រោះក្សត្រិយ៍អង្គនេះជារជ្ជទាយាទដោយត្រង់, តែក្នុងពេលមុនដែលព្រះបាទធរណេន្ទ្រវរ្ម័នសោយទិវង្គតនោះ, ( មិនដឹងជាក្នុងឆ្នាំណា ) ព្រះជយវរ្ម័នបានស្តេចយាងទៅគង់នៅក្រុងវិជ័យ ក្នុងដែនចម្ប៉ា គឺនៅស្រុកប៊ិញឌិញសព្វថ្ងៃនេះ ទុកព្រះទេវី នឹងព្រះឱរសតូច ១ អង្គ ឲ្យនៅក្នុងព្រះនគរឯណោះ ។ ការដែលព្រះជយវរ្ម័នទៅគង់នៅប្រទេសចម្ប៉ា ដោយទាក់ទាមដោយរឿង

សង្គ្រាម ឬដោយហេតុការណ៍អ្វី គេមិនអាចដឹងបានដោយច្បាស់លាស់ទេ ។ ក្រោយដែលស្តេចយាងទៅនោះ ព្រះរាជបិតាសោយទិវង្គតបង់វេលានោះរាជសម្បត្តិនៅទំនេរ ។ ព្រះជយវរ្ម័នដែលជារដ្ឋទាយាទ នឹងស្តេចយាងមកវិញ ឬមិនយាងមកទេ ក៏មិនអាចដឹងបាន រាជការមុខក្រសួងបានចាត់បំរើឲ្យនាំសារពត៌មានអំពីរឿងព្រះរាជបិតាសោយទិវង្គតទៅថ្វាយក្តាម តែយឺតយូរក្របានទៅដល់ ព្រោះលំបាកដោយគមនាគម ។

ជាធម្មតាទេ រឿងរាជសម្បត្តិ រមែងជាទីប្រាថ្នាយ៉ាងក្រៃពេករបស់ខត្តិយជាតិទាំងឡាយ (សមដូចសុភាសិតថា "យក្ខនឹងសាច់ ស្តេចនឹងរាជ្យ") ពិតដូច្នេះ កាលព្រះបាទធរណិន្ទ្រវរ្ម័នទី ២ សោយទិវង្គតហើយ ព្រះជយវរ្ម័នក្រយាងមកដល់ក៏ជាឱកាសឲ្យក្សត្រិយ៍ ១ អង្គ ព្រះនាមយសោវរ្ម័ន តែមិនដឹងជាជាប់អំបូរវង្សអំពីព្រះមហាក្សត្រិយ៍អង្គណាបានព្រមដោយស្ម័គ្របក្ខពួក លើកចូលទៅក្នុងក្រុងស្រីយសោធរបុរៈឡើងគង់លើរាជបល្ល័ង្ក ហើយប្រកាសខ្លួនជាព្រះរាជាម្ចាស់ផែនដីកម្ពុជរដ្ឋតែម្តង ។ ក្នុងពេលនោះ សូម្បីមានរាជសេវកាមាត្យនឹករស្តាយខ្លះដែលមិនទាន់ស្ម័គ្រចូលជាបក្ខពួក តែមិនអាចទឹងកំចាត់ចេញបាន ក៏គោរពតែព្រមទទួលស្គាល់ ដោយទាំងមិនពេញចិត្តនោះទៅ ប្រាកដព្រះបរមនាមថា ព្រះបាទយសោវរ្ម័នក្នុងរវាង ព. ស. ១៦៩៨ - ១៧០៨, គ. ស. ១១៥៥ - ១១៦៥ ដោយហេតុព្រះនាមនេះស្ទួននឹងព្រះនាមរបស់

ព្រះមហាក្សត្រិយ៍ ១ អង្គដ៏មានមកខាងដើម គេទើបរាប់ជាទី ២ ដើម្បីកុំឲ្យច្រឡំគ្នា ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្ដេច នឹងមានព្រះរាជឱរសព្រះរាជធីតាប៉ុន្មានទេ មិនប្រាកដ ៗ តាមអាកប្បកិរិយានៃព្រះបាទយសោវរ្ម័នដែលទ្រង់ឡើងសោយរាជ្យនោះ ឈ្មោះថា មិនត្រឹមត្រូវតាមលក្ខណៈច្បាប់រាជសន្តតិវង្ស ត្រូវទុកជាក្បត់ ដែករាជ្យរបស់ព្រះជយវរ្ម័ន អ្នកដែលក្បត់-ដែករាជ្យដោយមិនមានហេតុដ៏សមគួរបែបនេះ មិនត្រូវបានចារឹកនាមរាប់រៀងក្នុងបញ្ជីបុព្វកាក្សត្រិយ៍ទាំងពួង ដូច្នេះព្រះនាមនៃព្រះបាទយសោវរ្ម័ន ទើបត្រូវស្រែតមកនៅក្នុងផ្លូវរឿងទៅវិញ ។

បំណែកឯព្រះជយវរ្ម័ន កាលទ្រង់ជ្រាបពត៌មានរឿងព្រះរាជបិតាសោយទិវង្គតហើយ ទ្រង់ក៏គិតនឹងត្រឡប់ព្រះនគរដោយរួសរាន់, តែតមកមិនយូរ ទ្រង់បានជ្រាបថាមានរាជសត្រូវឡើងគង់លើរាជបល្ល័ង្កទៅហើយ ទ្រង់តុះតុញព្រះហឫទ័យ ដោយទ្រង់ព្រះចិន្តាថា បើតាមករណីត្រូវតែទ្រង់យាងត្រឡប់ភ្លាម តែថាប្រសិនជាត្រឡប់មក ក្រែងព្រះបាទយសោវរ្ម័នរករឿងរំលាងដោយបំពាន ទ្រង់មិនទុកព្រះហឫទ័យថា ទ្រង់អាចនឹងការពារព្រះអង្គឯងបាន, បើមិនមក នឹងខូចប្រយោជន៍យ៉ាងធំ ៗ ក្នុងទីបំផុត ទ្រង់សម្រេចព្រះហឫទ័យថា ត្រូវបង្អង់សិន រង់ចាំបានឱកាសស្រួលទៅថ្ងៃក្រោយ សឹមយាងមកគង់ ៗ

ខាងបំណែកព្រះបាទយសោវរ្ម័ន តាំងពីបានឡើងគ្រងរាជបល្ល័ង្ក

ហើយក៏មិនស្ងួវជាបានសុខសាន្តប៉ុន្មាន ដោយមានការណ៍បះបោរក្នុងប្រទេសជាញឹកញយ ទាំងនេះដោយហេតុនៃការគ្រងរាជសម្បត្តិរបស់ព្រះអង្គមិនប្រកបដោយគន្លងច្បាប់ ឬដោយហេតុប្រកបដោយអយុត្តិធម៌យ៉ាងដទៃជាបញ្ហា? ពោលចំពោះតែការណ៍បះបោរយ៉ាងធំៗ មានពីរដង:

បះបោរជាដំបូង ប្រាកដតាមសិលាចារឹក និងរូបភាពប្រកបនៅអមរេន្ទ្របុរៈ (បន្ទាយឆ្មារ) ថា មានជម្ពុជាតិអ្វីមួយដែលក្នុងសិលាចារឹកហៅថា ·រាហុ ឬករតេករាហុ មើលទៅរូបភាពក៏ប្រហែលរាហុ តែគង់មិនមែនរាហុ អសុរិន្ទ្រ ។ រាហុនេះកើតមានចិត្តទ្រើសទ្រនង់យង់ឃ្នងគិតដណ្តើមយកព្រះបរមរាជវាំងអំពីព្រះបាទយសោវរ្ម័ន, នាថ្ងៃមួយ រាហុបានទៅដល់ព្រះបរមរាជវាំង ពួកទាហានរក្សាព្រះរាជនិវេសន៍កាលរូបវិកលដូច្នោះក៏ភិតភ័យនាំគ្នារត់អស់ទៅ, តែក្នុងវេលានោះ មានព្រះកុមារជំទង់ ១ អង្គព្រះនាមលក្ខ័យេស ជាឧរសព្រះជយវរ្ម័ន (ទី ៧) បានព្រមដោយសេនាសំខាន់ ២ នាក់ចេញមកតយុទ្ធនឹងរាហុ ទ្រង់រាយរាហុនោះត្រូវត្រង់ក្តោងប្រមុះ ដួលផ្ងារទៅ, ព្រះបាទយសោវរ្ម័ន និងព្រះមហានគរក៏រួចផុតអំពីកណ្តាប់ដៃសត្រូវខ្មាត ។

មកក្នុងឆ្នាំទី ១០ រាប់ពីឆ្នាំសោយរាជ្យមក ព្រះបាទយសោវរ្ម័ន ត្រូវក្បត់ជាឧក្រិដ្ឋមួងទៀត ដោយមានមន្ត្រីធំ ១ នាក់ មិនប្រាកដឈ្មោះសឹងធ្លាប់ធ្វើរាជការក្នុងរជ្ជកាលព្រះបាទធរណេន្ទ្រវរ្ម័នទី ២ មានចិត្តលោភយសលើសលប់ ក៏តាំងរួបរួមស្ម័គ្របក្សពួកលើកទៅលុកក្រុងស្រីយសោធរបុរៈ ។

(មានត)

## ពុទ្ធសាសនា និង គ្រិស្តសាសនា

លោក ហ៊ុយ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

ប្រែពីទស្សនាវដ្ដី " ហ្វ្រង់អាស៊ី " ខែមិថុនាឆ្នាំ ១៩៥០

---

# អារម្ភកថាអ្នកបកប្រែ

រឿងនេះគឺជាសន្និសីទដែលលោកវេជ្ជបណ្ឌិត អង់ដ្រេមីហ្គូត៍ (André Migot) ឯតទគ្គបុគ្គលខាងបូព៌ាវិជ្ជានិយម បានធ្វើពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ ១៩៥០ នៅទីក្រុងដាឡាត់ ។ អត្ថបទនៃសន្និសីទនេះ លោកអង់-ដ្រេមីហ្គូត៍សំដែងអំពី "ពុទ្ធសាសនានឹងស៊ីវិល្យនៃបច្ចិមប្រទេសឲ្យឃើញថា តើមានសភាពជួយគ្នាឬស្របគ្នា" ។ ស្ដេចសង្ឃខាងគ្រិស្តសាសនា នាម ហ្វ. ប៉ារ៉ែល (F.Parrel) បានវិសជ្ជនាតបទៅវិញតាមនិទានកថា គឺ "ពុទ្ធសាសនានឹងស្ថានភាពនៃគ្រិស្តសាសនា" នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំដដែល ៗ រួចលោកវេជ្ជបណ្ឌិតអង់ដ្រេមីហ្គូត៍ បានថែមអវសាន និទ្ទេសមួយ គឺ "វិចារណញ្ញាណនិយមលទ្ធិ (dialectique)" ជាពាក្យអធិប្បាយដ៏ពីរោះពន់ពេក ។

យើងបញ្ជាក់ថា ការបុច្ឆាវិសជ្ជនានៃបណ្ឌិតខាងពុទ្ធសាសនា នឹងគ្រិស្តសាសនានេះ សឹងប្រកបដោយប្រាជ្ញាសុខុមគម្ភីរភាពខាងបរមត្ថ; ដោយលោកទាំងពីរនេះ ជាឯតទគ្គបុរសចំណានខាងពុទ្ធសាសនានឹង

គ្រិស្តសាសនា ហើយត្រូវយកឡាក់គោលសំខាន់ៗ មកត្រដាងបង្ហាញរៀងខ្លួន ប្រកបតាមវិចារណញ្ញាណផង តាមបណ្ឌិតភាពផង ដើម្បីនឹងផ្សាញ់គ្នាទៅវិញទៅមកដោយសច្ចភាព ។ លោកអ្នកអានប្រហែលជាមានសេចក្ដីពេញចិត្តនឹងអត្ថបទសន្និសីទទាំងនេះពុំខាន ព្រោះជាយុទ្ធវិធីខាងសាសនាមួយដែលលោកអ្នកពុំធ្លាប់បានជួប ។ បុច្ឆាវិសជ្ជនានេះមានជារវាងព្រះសង្ឃក្នុងពុទ្ធសាសនាទេសនាគ្រីស្ទ ដែលយើងធ្លាប់ឃើញ ធ្លាប់ដឹង ប្រៀបដូចជាមេទ័ពទាំងពីរចូលតយុទ្ធនៅទីសមរភូមិ ។

១ – សន្និសីទលោកអង់ដ្រេមីគូត

## ពុទ្ធសាសនានិងស៊ីវីល្យខាងបច្ចិមប្រទេស តើមានសភាពផ្ទុយគ្នា ឬស្របគ្នា ?

*"ពួកជាតិភ្ញុំស្ដាំង(១) ពុំមែនគ្រាន់តែមិនដឹងនូវលក្ខណៈនៃជីវភាពប្រជារាស្ត្រ ដែលស្ថិតនៅក្រៅជាតិរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងសុំឲ្យមនុស្សជាតិក្រៅពីជាតិរបស់ខ្លួន រៀបចំក្បួនខ្នាតនឹងរបៀបនៃការរស់នៅ ឲ្យដូចគ្នានឹងជីវភាពនៃជាតិរបស់ខ្លួនទៀត"* ។

លោកគីថ (Gœthe).

---

(១) ជាតិភ្ញុំស្ដាំង ក្រុមជារាស្ត្រអាស៊ីពីបុរាណកាល ចាកចេញពីកោះព្រែតមកតាំងកុលសម្ព័ន្ធនៅភាគប្រទេសស៊ីរី, សមុទ្រមីឌីទែរ៉ាណេ និងភូមិភាគស៊ុយ៉េ ។ ពួកអស្សីរីយ៉ាងបានទៅតស៊ូនឹងជាតិនេះ ពីកាលសតវត្សទី ៧ ជាតិនេះក៏បាត់តាមពីប្រវត្តិសាស្ត្រលោកតាំងពីកាលនោះមក ។

ខ្ញុំសូមអភ័យទោសអំពីលោកអ្នកទាំងអស់គ្នា ដោយខ្ញុំជាជាតិអឺរ៉ុប សូមថ្លែងអំពីព្រះពុទ្ធសាសនា(១) ចំពោះសវនដ្ឋាន (auditoire) ដែលមានសុទ្ធតែពួកពុទ្ធមាមកជនជាតិអាស៊ីដែលជាប្រភពនៃពុទ្ធសាសនានេះ ។ តែខ្ញុំអាចដឹងបានថា "លោកអ្នកជាជាតិបច្ចិមប្រទេសដែលអញ្ជើញមកក្នុងទីនេះដែរ លោកច្រើនមានគំនិតយល់ឆ្វេងឬកាន់ច្រឡំទៅតាមនិន្នាការ (tendances) សព្វៗខ្លួនថា ពុទ្ធសាសនាជានិមិត្តក្រៅដោយឡែកឬជាគំនរងងឹតនៃជនមិច្ឆាទិដ្ឋិ (Superstitions) ។ ចំណែកជនជាពុទ្ធមាមកៈច្រើនមិនបានស្គាល់ជាក់ច្បាស់នូវសាសនារបស់ខ្លួន ហើយមិនដែលគិតយកន័យខាងវប្បធម៌នៃសាសនារបស់ខ្លួន ទៅប្រៀបធៀបនឹងន័យខាងវប្បធម៌នៃសាសនានៃបច្ចិមប្រទេសនោះឡើយ" ។

ព្រះពុទ្ធសាសនាគឺជាការណ៍មួយដែលសំខាន់បំផុត ក្នុងចំណោមការណ៍ឯទៀតក្នុងប្រវត្តិសាស្ត្រលោក ហើយបានផ្សាយឥទ្ធិពលទៅកាន់ប្រទេសខាងចុងបូព៌ាអាស៊ីទ្វីបជាសម្បើមអស្ចារ្យ ហើយជាសាសនាដែលប្រជាកស្ថិតនៅរវាងប្រទេសឥណ្ឌៀនឹងជប៉ុន បាននិយមប្រព្រឹត្តប្រតិបត្តិតាមជាងសាសនាឯទៀត ។ ចំនួនទាយកនិងទាយិកា

១ អត្ថបទនេះគឺជាអត្ថកថា នៃសន្និសីទដែលបានធ្វើនៅថ្ងៃទី ១៤ ខែមេសា ឆ្នាំ ១៩៥០ ចំពោះសមាគមពុទ្ធសាសនានៅទីក្រុងដាឡាត់និងឡាំងបីយាង ។

ទាំងអស់មានកាត់មួយភាគបី នៃមនុស្សជាតិទាំងមូលក្នុងលោកសន្និវាសនេះ ។ ពួកជាតិខាងបូព៌ាអាស៊ីទ្វីប បានផ្តេកគំនិតខាងវប្បធម៌, សិល្បវិជ្ជា, អក្សរសាស្ត្រ អំពីពុទ្ធសាសនា, មួយទៀតពុទ្ធសាសនាជារបៀបអារ្យធម៌ដែលប្រៀបធៀបទៅ ប្រហែលនឹងអារ្យធម៌នៃគ្រិស្តសាសនានៃបច្ចិមប្រទេស ។ ការយល់នូវផ្លូវប្រាជ្ញាទាំងពីរបែបនេះត្រូវតែយើងស្គាល់ខានមិនបាន ព្រោះថាមនុស្សណាមួយដែលមិនស្គាល់នូវផ្លូវណាមួយខាងលើនេះ មនុស្សនោះគេទុកជាមនុស្សល្ងង់ខ្លៅបំផុត ។ ខ្ញុំមិនបានថ្លែងនូវលទ្ធិពុទ្ធសាសនា ឬពុទ្ធប្រវត្តិនោះទេ; សេចក្តីអួតអាងរបស់ខ្ញុំ ចំពោះមុខលោកអ្នកមានសភាពថយចុះជាងនោះ, ខ្ញុំបាទមានឯកសិទ្ធិរស់នៅជាច្រើនឆ្នាំ នៅប្រទេសដែលនិយមរាប់អានព្រះពុទ្ធសាសនា, ជួនកាលខាងហីនយានគឺប្រទេសស៊ីឡង់ (លង្កាទ្វីប) ភូមា, កម្ពុជា ជួនកាលខាងមហាយាន គឺប្រទេសវៀតណាម, ចិន, ទីបេតនឹងមុងហ្គោលី ។ ព្រោះខ្ញុំមានវត្តបំណងចង់ស្គាល់ឲ្យជាក់ច្បាស់នូវព្រះពុទ្ធសាសនា ចំពោះលទ្ធិនិងវិធីប្រតិបត្តិមានការប្រស្រ័យដោយមិត្តភាពនឹងព្រះសង្ឃព្រមទាំងពួកឡាម៉ា (lamas)[១] ។

(មានត)

១ ឡាម៉ា ព្រះសង្ឃនៅខាងភូមិភាគទីបេត (ប្រទេសចិន) ។

# ពន្លឺអាស៊ីទ្វីប

La Lumière de l'Asie

លោក ស៊ើរ-អេតវីនអារណូលដ៍ តែង

## លោកប៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(ត មក)

---

ក្នុងថ្ងៃមួយ មានពួកនារីមួយក្រុមត្រាច់ដើរតាមផ្លូវស្លៀកសំពត់កណ្តាប, គឺជាពួកនាងនាដកាហៅថា (nautch)[១] ដែលជាព្រះវិហារសក្កទេវរាជ ក្នុងនគរ, មានពួកប្រុសរបាំតាមមកជាមួយផង បុរសម្នាក់វាយស្គរដែលមានស្លាបក្ងោកដោតជាលំអសិល្បៈផង, ម្នាក់ទៀតប៉ងស៊ូ-លី[២] ដែលមានស័ព្ទសំឡេងខ្លាំងហើយម្នាក់ទៀតដេញពិណ (Cithare) មានខ្សែបី ៗ. នាងទាំងនោះបានត្រាច់ចុះពីលើភ្នំតូច, តាមផ្លូវជើងមួយ ដើម្បីនឹងទៅលេងសប្បាយឯកន្លែងបុណ្យអ្នកដទៃ; នាងពាក់កូនកណ្តឹងប្រាក់ឮសូររណ្តំគ្នានៅកជើងមានពណ៌ប្រផេះ ហើយមានកងដៃឮស័ព្ទស្នូរទង្គិចគ្នានៅដៃនឹងកដៃឆ្លើយឆ្លងគ្នាពីរោះអស្ចារ្យ; ចំណែកខាងអ្នកដេញពិណ ទំផ្លាត់ខ្សែស្ពាន់ ៗ នាងនាដកាម្នាក់នៅជិតអ្នកដេញពិណក៏តាំងច្រៀងថា:

---

១ (nautch) នាងនាដិកាទាំងប៉ុន្មាន គឺនៅនឹងវត្តអារាម ហើយមានមុខការដែលត្រូវបំពេញគឺច្រៀងនឹងរាំចំពោះរូបព្រះឬនាងទេវធីតា ។ នាងទាំងនេះគេជួលទៅរាំដែរក្នុងកាលបុណ្យជាសាធារណឬឯកជន ។

២ ប៉ាំងស៊ូលី ជា ពាក្យឥណ្ឌូគឺប្រដាប់ភ្លេងដូចជាក្ងូរនឹមូស (Cornemuse)

"ការរាំសប្បាយយើងចាប់ផ្ដើមហើយ ដូច្នេះគួរតែខ្សែពិណឲ្យត្រូវសូរពីរោះ សូមអ្នកតែខ្សែពិណកុំឲ្យតឹងពេក ធូរពេក យើងនឹងធ្វើឲ្យរំជួលនូវហឫទយវត្ថុរបស់មនុស្សទាំងអស់" ។

"ខ្សែពិណ បើតឹងពេកនឹងដាច់ ហើយសូរស័ព្ទអណ្ដែតបាត់; ខ្សែពិណធូរពេកមិនត្រូវសូរ ហើយសូរភ្លេងក៏បាត់ស្ងាត់; ឱអ្នកដេញពិណ សូមតែខ្សែពិណកុំឲ្យខ្ពស់ពេក ទាបពេក" ។

នេះជាចំរៀងនាងនាដការឲ្យត្រូវគ្នានឹងសំឡេងភ្លេង "គូរណីមុស" ផ្សំនឹងខ្សែភ្លេង ហើយនាងរាំតាមចង្វាក់ភ្លេង ដូចជាមេអំបៅស្រាលហើរលើនភាល័យ ពីព្រៃមួយទៅព្រៃមួយ ។ នាងត្រាច់តាមផ្លូវក្នុងព្រៃ ដោយមិនបានគិតថា បទចំរៀងនោះចេញពីមាត់នាងអណ្ដែតត្រសែត ទៅចូលព្រះស្រោតព្រះពោធិសត្វដែលកំពុងគង់ក្រោមអដ្ឋបាលនិគ្រោធមួយដើម ជិតផ្លូវដើរមួយហើយព្រះទ័យព្រះអង្គចុះទៅក្នុងឈានចិត្ត ។

ក្នុងឱកាសដែលពួកក្រមុំនោះមកដល់ទីនោះហើយ ព្រះពោធិសត្វងើយនលាដ មានព្រះឱង្ការថាៈ បណ្ឌិតអាចយកអាការរបស់មនុស្សឆ្កួតមកទូន្មានប្រដៅខ្លួនបាន អាត្មាអញប្រហែលតែខ្សែរវង្គនៃជីវភាពហួសប្រមាណដោយចង់ឲ្យត្រូវស័ព្ទសូរពីរោះគឺធម៌ពិត ដែលអាចជួយស្រោចស្រង់សត្វលោកបាន, តែអាត្មាអញប្រែទៅជាងងឹត, ដល់ពេលដែលនឹងត្រូវឃើញសច្ចធម៌ កាយអាត្មាអញទុព្វលភាពណាស់

ដល់ពេលឥឡូវអាត្មាអញកំពុងត្រូវការនូវកំឡាំង, ប៉ើក្នុងពេលនេះ អញមិនមានអ្នកណាមកជួយទេ អាត្មាអញមុខជាមរណៈ ខ្លួនអាត្មាអញគួរធ្វើឲ្យមានជីវភាពជាទីសង្ឃឹមនៃមនុស្សទាំងអស់តទៅអនាគត "

ក្នុងពេលនោះ នៅតាមមាត់ស្ទឹង មានបុគ្គលម្នាក់ជាអ្នកពេញចិត្តខាងសាសនា ហើយជាអ្នកមានភោគទ្រព្យស្តុកស្តម្ភ មានហ្វូងបសុសត្វជាច្រើន ហើយជាអ្នកមានចិត្តសប្បុរសជាកល្យាណមិត្តនឹងពួកកំសត់-ទុគ៌ត, ភូមិនោះ គេហៅថា "សេនានិគម" ដោយយកនាមមកពីវង្សត្រកូលបុគ្គលនោះបានរស់នៅក្នុងភូមិនោះជាសុខសប្បាយ ទឹងភរិយាឈ្មោះនាងសុជាតា ដែលជានារីមានរូបឆោមលោមពណ៌គួរជាទីពេញចិត្តមានភ្នែកខៀវដូចស្នាទកាពនៃពល, នាងមានកិរិយាស្លូតត្រង់, ចិត្តរាបសាប្រកបដោយប្រិយភាព; បុកពានាងខ្ពង់ខ្ពស់, នាងពោលពាក្យជាបិយវាចា ហើយពោលកន្ទុយភ្នែកញញឹមស្រស់ រួមសេចក្តីទៅថា: នាងជាឯកនារី ប្រសើរលើសស្ត្រីទាំងអស់ នាងរស់នៅជាមួយនឹងស្វាមីក្នុងគេហដ្ឋានដោយសុខសប្បាយ; នាងមានព្រួយបារម្ភតែមួយយ៉ាងគឺតាំងពីពេលសមរសមកដល់ឥឡូវនេះនាងគ្មានកូនប្រុសសោះ ៗ ព្រោះហេតុដូចនេះ បានជានាងបន់ព្រះលក្ខ្មី[១] ហើយជាច្រើនយប់មកហើយក្នុងពេលដែលព្រះចន្ទកំពុងពេញបូណ៌មី នាងបានទៅធ្វើប្រទក្សិណ

---

១ លក្ខ្មី ជាអគ្គជាយានៃវិស្ណុ ជាទេវធីតាមានសម្បូណ៌ភាពជាបដិមា ដូចជាតាងសេរីរសខាងសាសនាក្រឹក ។

ប្រាប្អូនជុំនូវអ្នកតា "លិង្គម" (១) ហើយបានបូជានូវបាយកម្រងផ្កា ម្ទេះ ប្រេងកំញានដើម្បីទឹងសូមឲ្យបានកូនប្រុសមួយ; នាងសុជាតា បានអធិដ្ឋានក្នុងចិត្តចំពោះ អ្នកតាព្រះរៃដ បើបំណងនោះបានសម្រេចដូច សេចក្ដីប្រាថ្នាវេលាណា ទើបនាងថ្វាយនូវមធុបាយាសជាក្រយាហារ ដែលទេវតាតែងពេញចិត្តនឹងសោយ . នាងដាក់ទឹងសុវណ្ណភាជន៍យក តំកល់នៅក្រោមដើមពោធិព្រឹក្សនោះ ។ បំណងរបស់នាងក៏បានសម្រេច ក្នុងពេលនោះ ដោយនាងបានប្រសូតបុត្រប្រុសមួយ ឥឡូវកូននោះ អាយុបានបីខួបហើយ ដោយនាងកតញ្ញូគុណក៏ត្រាប់ទៅកាន់ទីទេវតាក្នុង អរញ្ញប្រទេសនោះ ដៃម្ខាងកាន់សំពត់ព្រៃសារក្រហមឆ្អៅសម្រាប់រុំ ទារក ដែលជាថ្មើមប្រមាត់របស់នាង, ដៃម្ខាងទៀត នាងបន្ទន់ឲ្យទាប កាន់ទប់នូវភាជន៍ឲ្យទឹងនៅលើក្បាលនាង ដែលដាក់ភោជនាហារដ៏មាន ឱជារសសម្រាប់បូជា ។

តែនាងទាសីឈ្មោះរដ្ឋា ( Radba ) ដែលនាងបានចាត់ឲ្យទៅបោស សំអាតក្រោមដើមដៃហើយយកខ្សែក្រហមរុំព័ទ្ធដើមឈើនោះ នាងវិល ត្រឡប់មកវិញជំរាបនាងសុជាតាថា: ឱព្រះនាង! សូមអញ្ជើញទៅ មើលទេវតានៅក្នុងព្រៃបញ្ចេញរូបឲ្យឃើញជាក់ច្បាស់, គង់នៅទីនោះ,

(មានត)

---

១ លិង្គ ដុំថ្មចំឡាក់មូលវែង ជាបដិមាធំតួលិង្គព្រះឥសូរ ជាតាមធម៌ចំពោះពល-ភាពក្នុងការស្ថាបនាលោក ។

និជ្ជធម្មកត្តកថា

# ព្រះទេពសត្ថា សូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

ទេសនាផាក់វិទ្យុនៅថ្ងៃ ៨ រោចខែស្រាពណ៍ ព. ស. ២៤៩១ - ៨ - ៩៤៨

នមត្ថុរតនត្តយស្ស

*អស់លោកអ្នកស្ដាប់ទាំងឡាយ !*

*ពេលនេះជាមង្គលមួយដ៏ប្រសើរ ដែលអាត្មាភាពត្រូវវេនមកសំដែងធម៌អំពីប្រយោជន៍បច្ចុប្បន្ន ដើម្បីជាសណ្ដាប់នៃអស់លោក-អ្នកទាំងឡាយដូចសេចក្ដីដែលត្រូវសំដែង ព្រមទាំងអធិប្បាយតទៅនេះ:*

## ប្រយោជន៍បច្ចុប្បន្ននេះមាន ៤ យ៉ាង

*១ – ឧដ្ឋានសម្បទា = ការគ្រប់គ្រាន់ដោយការក្រោកឡើង*

*២ – អារក្ខសម្បទា = ការគ្រប់គ្រាន់ដោយការរក្សាថែទាំ*

*៣ – កល្យាណមិត្តតា = ភាពនៃបុគ្គលជាអ្នកមានមិត្តល្អ*

*៤ – សមជីវិតា = ភាពនៃបុគ្គលជាអ្នកមានការចិញ្ចឹមជីវិតសមគួរ ។*

## អធិប្បាយប្រយោជន៍ទី ១

*ការបរិបូណ៌ដោយហេតុដែលគួរប្រកប ដើម្បីឲ្យបានសម្រេចដូចបំណង ហៅថា សម្បទា ។ សម្បទានេះ ប្រែថា "គ្រប់គ្រាន់, ជាគុណជាតិជាគ្រឿងផ្ដល់ ឬជាគ្រឿងប្រគល់ឲ្យនូវប្រយោជន៍" ។*

• ឧដ្ឋានសម្បទា ដែលប្រែថា "ការគ្រប់គ្រាន់ដោយការក្រោកឡើង" នោះតើក្រោកឡើងប្រកបការងារដូចម្តេច? ការងាររបស់មនុស្សដែលត្រូវប្រកបក្នុងលោកនេះ មានច្រើនយ៉ាងគឺការងារខ្លះធ្ងន់, ខ្លះស្រាល, ខ្លះធំ, ខ្លះតូច; ការងារខ្លះជាប្រយោជន៍ផ្ទាល់ខ្លួន, ខ្លះជាប្រយោជន៍សាធារណៈ; ការងារខ្លះប្រកបដោយទោស, ខ្លះប្រាសចាកទោស; ការងារខ្លះបានផលច្រើន, ខ្លះបានផលតិច តាមគ្រាន់ហេតុរបស់ការងារនោះៗ ។

បណ្តាការងារទាំងអស់ក្នុងលោកនេះ, ការងារណាក៏ដោយ តាំងអំពីការសិក្សារៀនសូត្រ ធ្វើស្រែចំការជួញប្រែជាដើមនោះ សុទ្ធតែត្រូវប្រកបដោយឧដ្ឋាន: គឺការក្រោកឡើងម្នីម្នារៀសរវៃ ប្រញាប់ចាប់កិច្ចការដែលខ្លួនត្រូវធ្វើដោយម៉ត់ចត់ទាំងអស់ ទើបសម្រេចផលដូចបំណងទៅបាន, បើមិនច្រើនក៏តិចតាមកំឡាំងនៃការងារនឹងកំឡាំងនៃសេចក្តីព្យាយាម ។

ការងារទាំងឡាយដែលត្រូវប្រកបចុះដៃធ្វើនោះ ច្រើនតែមានហេតុចង្រៃមករាំងខ្ទាំងខ្ទាស់ឬដែលហៅថាមារដែក បាលីហៅថាឧបសគ្គ ។ បើការងារតូចថោកទាប មានឧបសគ្គបន្តិចបន្តួច, បើការងារធំខ្ពង់ខ្ពស់ មានឧបសគ្គក៏ច្រើន; ឧបសគ្គនេះតែងតាមប្រណាំងប្រជែងបៀតបៀនការងារទាំងអស់ធម្មតា ។ សេចក្តីព្យាយាមក្នុងការងារដែលចេះតែក្លាយចេះតែខកខាន ក៏ព្រោះឧបសគ្គនេះឯង ។

សេចក្ដីប្រឹងប្រែងខ្មីឃ្មាតក្រោកឡើងមម៉ឺមមានេះ តាមបាលីហៅថា ឧដ្ឋានៈ; ពាក្យថា ឧដ្ឋានៈនេះ ជាឈ្មោះនៃសេចក្ដីព្យាយាមដែលមានកំឡាំងក្លៀវក្លា ។

ពាក្យថា ព្យាយាមនេះ ខ្មែរយើង មានពាក្យវេវចនស័ព្ទ គឺសំដីដែលនិយាយផ្លាស់ប្ដូរជាច្រើនយ៉ាង, ភាសាបាលីក៏មានវេវចនស័ព្ទច្រើនយ៉ាងដែរ ។ ដូចឧដ្ឋានៈ = ការក្រោកឡើង, វិរិយៈ = ប្រាសចាកសេចក្ដីរួញរា, វាយាមៈ = ព្យាយាមប្ដូឈានទៅមុខ, ឧស្សាហៈ = ខ្មីឃ្មាត, បរក្កមៈ = ទទូច, អដ្ឋិតិ = មិនឈប់នៅ, អប្បដិវានី = មិនត្រឡប់ថយក្រោយ, អនិក្ខិត្តឆន្ទតា = មិនបោះបង់សេចក្ដីប្រាថ្នា, អសិថិលបរក្កមតា = ទំប្រឹងប្រែងមិនបន្ធូរបន្ថយ, អនិក្ខិត្តធុរតា = មិនដាក់ធុរៈចោល ។

សេចក្ដីខ្នះខ្នែងក្រវើនក្រវើនកងកិច្ចការ មិនបណ្ដែតបណ្ដោយមិនធ្វេសប្រហែសពាយឆាយ, មិនខ្ជិលខ្ជា គឺមានភាពជាអ្នកស្រវាស្រទេញស្រឡាញ់ការងារដែលខ្លួនត្រូវធ្វើ, មិនខ្លាចលំបាក, មិនគិតពីការហត់នឿយ, ទំប្រឹងកំចាត់នូវកោសជ្ជៈសេចក្ដីខ្ជិលច្រអូសចេញចាកខន្ធសន្ដាន; ព្រោះថាកោសជ្ជៈនេះជាទំនាស់គ្នានឹងសេចក្ដីព្យាយាម ; ទោះបីមានឧបស័គ្គយ៉ាងណា ក៏មិនត្រូវទំលាក់ការដែលខ្លួនធ្វើនោះចោលឡើយ ។

ឧបសគ្គ សេចក្ដីចង្អៀតខ្ទាំងខ្ទប់ នឹងសាបរលាបរលាយបាត់ទៅ ក៏ព្រោះសេចក្ដីព្យាយាម ។ បុគ្គលអ្នកមានសេចក្ដីព្យាយាមប្រឹងប្រែង ទុកដូចជាអ្នកមានថ្នាំឧសថវិសេស សម្រាប់បន្សាបនូវពិសកាច គឺ ឧបសគ្គ នឹងកោសជ្ជៈឲ្យស្ងប់ម្ងាប់ ។ បុគ្គលអ្នកមានព្យាយាម រមែងចំរើនចំរុងថ្កើងដោយទ្រព្យធននឹងយសបរិវារ ប្រសើរលើសជាងបុគ្គលអ្នកខ្ជិលច្រអូសដោយពិត ។

ព្រះសម្ពុទ្ធជាម្ចាស់ ដែលទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណត្រាស់ដឹងឡើង ព្រោះតែសេចក្ដីព្យាយាមនេះឯង ។ សេចក្ដីព្យាយាមនេះជាបារមី ១ ដ៏ប្រសើររបស់ព្រះពោធិសត្វ ដែលកំពុងកសាងនៅឡើយ ហៅថា វិរិយបារមី ។ មួយទៀតការព្យាយាមមិនរួញរានេះ ជាកំឡាំងមួយធំបំផុត ហៅថា វីរិយពលៈ ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងហើយ ឧស្សាហ៍ប្រោសប្រទានធម៌ទេសនាអំពីសេចក្ដីព្យាយាមនេះជាញឹកញយណាស់ ចំពោះពុទ្ធបរិសទ្យទាំងគ្រហស្ថនឹងបព្វជិត ដាស់តឿនមិនឲ្យខ្ជិលច្រអូសដំអក់ទំនេរក្នុងកិច្ចការដែលខ្លួនត្រូវធ្វើ ដើម្បីឲ្យបានចំរើនប្រយោជន៍ក្នុងបច្ចុប្បន្ន ។

សេចក្ដីព្យាយាមនេះឈ្មោះថាជាឥដ្ឋារម្មណ៍ គឺ អារម្មណ៍ជាទីប្រាថ្នា ជាទីស្រឡាញ់របស់អ្នកប្រាជ្ញគ្រប់សម័យ ។ ចំណែកខាងកោសជ្ជៈ សេចក្ដីខ្ជិលច្រអូសឈ្មោះថាជានិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នា

មិនជាទីស្រឡាញ់របស់អ្នកប្រាជ្ញទាំងឡាយ តាំងពីកាលណាមក ។ សាសនធម៌ គឺពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញក្នុងលោកមានព្រះពុទ្ធជាដើម តែងមានការសរសើរសេចក្តីព្យាយាមនេះរឿយៗណាស់ ។

អ្នកប្រាជ្ញទាំងអស់ក្នុងលោកមិនរើសថា អ្នកប្រាជ្ញក្នុងសាសនាណាទេ សុទ្ធតែស្រឡាញ់សេចក្តីព្យាយាម ស្អប់សេចក្តីខ្ជិល, សូម្បីគ្រូអាចារ្យមាតាបិតារបស់យើង ក៏ស្រឡាញ់អ្នកមានព្យាយាម ស្អប់មនុស្សខ្ជិលដែរ ។ ព្រោះថាសេចក្តីព្យាយាមនេះ ជាគុណនាំឲ្យភ្ញាក់ដឹងខ្លួនទាន់កាលសម័យ ហើយអាចឈោងចាប់យកប្រយោជន៍បានភ្លាមៗ គឺនាំឲ្យចំរើនភោគសម្បទ, រដ្ឋសម្បត្តិ និងបរិវារសម្បត្តិ, ចំណែកខាងសេចក្តីខ្ជិលប្រអូសជាទោសមួយធំបំផុត ដែលនាំឲ្យប្រទេសជាតិអាប់ឱនលិចលង់ឲ្យលង់ទៅ ឲ្យឃ្លាងចាកប្រយោជន៍ដែលគួរបានតាមកាលសម័យ គឺនាំឲ្យវិនាស ក្រខ្សត់ខ្សោយថោកទាបរហេមរហាមជាដរាបក្នុងបច្ចុប្បន្ននេះ ។ បុរសស្ត្រីអ្នកមានព្យាយាម តែងបាននូវលាភយសពេញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ទោះបីបុគ្គលមិនសូវមានបុណ្យព្រេងអំពីជាតិមុនច្រើនក៏ដោយ តែបើជាអ្នកប្រកបដោយសេចក្តីព្យាយាមជាប់ល្អហើយ ទៀងតែនឹងបានឋានន្តរទីដំណែងដ៏ប្រសើរ បើមិនបានធំក៏តូចមិនខាន ។ បុគ្គលអ្នកមានព្យាយាមត្រូវទទួលផលប្រយោជន៍ គតមានទោសទាស់នឹងច្បាប់ពុទ្ធសាសនាឡើយ ។

សេចក្ដីព្យាយាមនេះ មានអានិសង្សឲ្យឃើញជាក់លាក់ក្នុងលោក ទុកដូចជាស្នេហ៍មុខមួយសម្រាប់ប្រគល់ឲ្យនូវគុណគឺ លាភយសសរសើរ សុខ ដល់បុរសស្ត្រីអ្នកមានព្យាយាមនោះវិញ ។ សមដូចពុទ្ធភាសិតថា បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ បុគ្គលអ្នកមានធុរៈទទួលកាន់ការប្រឹងប្រែងរមែងបាននូវទ្រព្យសម្បត្តិ, វីរិយេន ទុក្ខមច្ចេតិ បុគ្គលកន្លងនូវទុក្ខព្រួយបានក៏ព្រោះព្យាយាម, វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា បុគ្គលជាកូនប្រុសគួរប្រឹងប្រែង កុំលែងឲ្យទាល់តែសម្រេចប្រយោជន៍, ទឡ្ហមេតំ បរក្កមេ ត្រូវប្រឹងប្រែងចំពោះការនោះឲ្យមាំមួន ” ។

បុគ្គលអ្នកមានប្រាថ្នាសេចក្ដីសុខចំរើនរុងរឿង ត្រូវតែមានព្យាយាមឲ្យស្វិតស្វាញក្នុងកិច្ចការទាំងពួង តាមរយៈកាលនៃវ័យទាំង ៣ គឺ បឋមវ័យ ជាកាលត្រូវទទួលធុរៈខាងការសិក្សាអក្សរសាស្ត្រនិងវិទ្យាសាស្ត្រផ្សេងៗ, មជ្ឈិមវ័យ ជាកាលត្រូវស្វែងរកភោគសម្បទ, បច្ឆិមវ័យ ជាកាលត្រូវប្រព្រឹត្តសីលធម៌ ដើម្បីឲ្យសមតាមថ្នាក់ជាមនុស្សចាស់ទុំ ។ សេចក្ដីអធិប្បាយមកនេះហៅថា ឧដ្ឋានសម្បទា ។

## អធិប្បាយប្រយោជន៍ ទី ២

ការគ្រប់គ្រាន់បរិបូណ៌ដោយគំនិតមាំយ៉ាង ដែលចេះរក្សាទ្រព្យ-ធនមិនឲ្យវិនាសបង់ដោយអន្តរាយផ្សេងៗ មានអន្តរាយដោយភ្លើងឆេះ

ទឹកលិច ចោរលួចជាដើម ។ ការបេះទុកដាក់លាក់រក្សារៀបចំទ្រព្យសម្បត្តិទាំងខាងក្នុងផ្ទះទាំងខាងក្រៅផ្ទះដោយការប្រយ័ត្ន មិនភ្លេចគ្រប់វេលាយប់ថ្ងៃ នេះជាហេតុ ១ ដ៏ប្រសើរដែលនាំឲ្យគង់ទ្រព្យសម្បត្តិចំរើនដល់ខ្លួនទីងវង្សត្រកូលរបស់ខ្លួនវែងឆ្ងាយតទៅ ។ បុរសស្ត្រីក្នុងត្រកូលណាមួយ ដែលធ្លាប់បានចំរើនមានសម្បត្តិ ហើយត្រឡប់ទៅជាធ្លាក់ខ្លួនថោកទាបក្រខ្សត់វិញនោះ ក៏ព្រោះហេតុតែមិនបរិបូណ៌ដោយការរក្សាថែទាំ ដែលហៅថាខ្វះប្រហែសភ្លេចស្មារតី ហៅថាខ្វះអារក្ខសម្បទា ។ ដូចបុគ្គលខ្លះក្នុងលោកនេះ មានទ្រព្យសម្បត្តិត្រឹមតែមួយជីវិតខ្លួនក៏មាន មិនដល់មួយជីវិតក៏មាន, មានទ្រព្យសម្បត្តិជាប់យូរអង្វែងរហូតដល់ច្រើនតំណត្រកូលទៅក៏មាន ។

បុគ្គលដែលមានភោគសម្បទ៍ស្តុកស្តម្ភហើយ មិនតាំងនៅយូរបាន ដោយហេតុ ៤ យ៉ាងគឺ នដ្ឋំ ន គវេសន្តិ មិនស្វែងរកទ្រព្យធនដែលវិនាសខូចខាតហើយ ១, ជិណ្ណំ នប្បដិសង្ខរោន្តិ មិនជួសជុលអបស្លបរបស់ដែលចាស់គ្រាំគ្រា ១, អបរិមិត្តភោជិកា ហោន្តិ ជាអ្នកប្រើប្រាស់របស់មិនមានកំណត់ប្រមាណ គឺជាបុគ្គលខ្ជះខ្ជាយហួសហេតុ ១, ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬបុរសទ្រុស្តសីល ទុកក្នុងទីជាអធិបតី គឺជាអ្នកកាន់ការផ្ទះ ១ ។ ត្រកូល

ដែលធ្លាក់ចោកទាបទៀតហើយទៅជាក្រទាល់ ដោយហេតុ ៤ ប្រការនេះ ឯង ។ ត្រកូលនេះឈ្មោះថាខ្វះការក្ខសម្បទា ។

ចំណែកត្រកូលអ្នកមានភោគសម្បទ័ស្តុកស្តម្ភជាប់យូរអង្វែងច្រើន គំណៅបាន ក៏ព្រោះតែហេតុ ៤ ប្រការ គឺ **នដ្ឋំ គវេសន្តិ** ស្វែងរកទ្រព្យធនដែលវិនាសខូចខាត ១, **ជិណ្ណំ បដិសង្ខរោន្តិ** ជួសជុលអបស្តុបរបស់ដែលចាស់គ្រាំគ្រា ១, **បរិមិតភោជនា ហោន្តិ** ជាអ្នកប្រើប្រាស់របស់មានកំណត់ប្រមាណមិនខ្ជះខ្ជាយ ១, **សីលវន្តិ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ** តាំងស្ត្រី ឬ បុរសមានសីលធម៌គុណទីជាអធិបតី គឺជាអ្នកកាន់ការផ្ទះ ១ ។

បុគ្គលដែលប្រកបដោយហេតុ ៤ យ៉ាងនេះ ឈ្មោះថាជាអ្នកប្រកបដោយការក្ខសម្បទាដ៏គប់គ្រាន់ ។

## អធិប្បាយប្រយោជន៍ទី ៣

បុរសស្ត្រីដែលកើតមកក្នុងលោកនេះ ទោះជាបុគ្គលជាន់ខ្ពស់ក្តី ជាន់ទាបក្តី នឹងនៅតាមទំនើងខ្លួនឯងម្នាក់ៗ ពុំបានឡើយ ត្រូវតែមានការសេពគប់ពប់រកទទួលស្គាល់អ្នកដទៃផងជាដរាប ។ បុគ្គលដែលគេសេពគប់ក៏មានច្រើនពួក គឺជាពួកមនុស្សពាលទុច្ចរិតក៏មាន, មនុស្សកណ្តាលៗល្មមសេពគប់បានក៏មាន, មនុស្សជាបណ្ឌិតក៏មាន ។ ការសេព

គប់នេះជាការសំខាន់បំផុត គឺជាមូលហេតុជាបច្ច័យនាំឲ្យបានទទួលទុក្ខទោសក៏មាន, នាំឲ្យបានសុខចំរើនឡើងក៏មាន, ព្រោះហេតុនោះការសេពគប់នេះ ត្រូវប្រយ័ត្នឲ្យណាស់ បើប្រទះនឹងបុគ្គលពាលហើយគប់រកដោយពេញចិត្ត ចូលគំនិតនឹងបុគ្គលពាល រមែងនាំមកនូវសេចក្ដីវិនាសឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ។

ការសេពគប់នឹងបណ្ឌិតដែលជាអ្នកមានសីលធម៌ល្អ រមែងនាំមកនូវសេចក្ដីសុខសួស្ដី ។ ការសេពគប់មនុស្សពាលឈ្មោះថាជាការសេពខុសដែលនាំឲ្យខាត ។ ការសេពគប់បណ្ឌិត ឈ្មោះថាជាការសេពគប់ត្រូវ ដែលនាំផ្លូវឲ្យបានចំណេញ ឲ្យសុខចំរើនឥតអាក់ដោយពិត ។ ការសេពគប់នេះ ជាដើមផ្លូវនៃការខូចខាតនឹងការចំរើន ហេតុនោះត្រូវយើងពិនិត្យសង្កេតមើលឲ្យជាក់លាក់ · ត្រូវសេពគប់ចំពោះតែមនុស្សដែលមានសីលធម៌ល្អ ជាកល្យាណមិត្រ ទើបសម្រេចប្រយោជន៍ដូចបំណងក្នុងបច្ចុប្បន្ននេះបាន ។

## អធិប្បាយប្រយោជន៍ទី ៤

ការលៃលកបែងចំណែកទ្រព្យសម្បត្តិ ទំនុកបំរុងជីវិតឲ្យសមគួរតាមកំឡាំងទ្រព្យសម្បត្តិដែលរកបាន មិនឲ្យខ្ជះខ្ជាយពេក មិនកំណាញ់រឹតត្បិតពេក ដើម្បីឲ្យជាប្រយោជន៍បានសុខទាំងចំណែកខ្លួននឹងអ្នកដទៃ ។ ការចាយវាយខ្ជះខ្ជាយនោះ ជាហេតុឲ្យកើតវិប្បដិសារៈ ក្ដៅ

គ្រហាយស្ដាយក្រោយក្នុងកាលដែលខ្លួនអស់ទ្រព្យសម្បត្តិ; ការចាយវាយកំណាញ់ត្បិតត្បៀតហួសហេតុពេកនោះ ក៏ជាហេតុឲ្យមានគេហានិន្ទា ដែលមិនជាទីស្រឡាញ់មេត្រីពេញអាន នៃពួកជនទាំងពួងក្នុងផ្ទះទាំងខាងក្រៅផ្ទះ ព្រោះហេតុនោះ ការប្រើប្រាស់ទ្រព្យសម្បត្តិដែលប្រកបដោយលក្ខណៈត្រឹមត្រូវជាប្រយោជន៍ប្រសើរ ។

អ្នកមានទ្រព្យសម្បត្តិ ដឹងប្រមាណក្នុងការចាយវាយ ជាហេតុឲ្យកើតសេចក្ដីកក់ក្ដៅក្នុងចិត្ត, ទ្រព្យសម្បត្តិដែលស្វែងរកបានមកហើយនោះមិនមែនសម្រាប់ចំពោះតែខ្លួនឯងម្នាក់ទេ ត្រូវតែបែងចំណែកទ្រព្យសម្បត្តិចេញជា ៥ ចំណែក គឺ ចាយវាយដើម្បីឲ្យសុខស្រួលដល់ខ្លួនឯងនិងមាតាបិតា បុត្រធីតារបស់ខ្លួន ១, ដើម្បីឲ្យសុខស្រួលដល់ញាតិមិត្រដែលគួរសង្គ្រោះ ១, សំចៃទ្រព្យសម្បត្តិទុកការពារអន្តរាយ ១, ធ្វើទក្ខិណាទានក្នុងសាសនា ១, ធ្វើពលីទាំង ៥ យ៉ាង មានញាតិពលីជាដើម ១ ។

ការបែងចំណែកទ្រព្យសម្បត្តិត្រូវតាមដំណើរ ៥ យ៉ាងនេះ ហៅថាសមជីវិតា ដែលប្រែថា ការចិញ្ចឹមជីវិតដ៏ល្មមសមគួរ គឺមិនខ្ជះខ្ជាយហួសទ្រព្យសម្បត្តិដែលខ្លួនរកបាន មិនរឹតត្បិតហួសខុសគម្រោពេក ។ បុគ្គលជាគ្រហស្ថប្រុសស្រី អ្នកដែលប្រាថ្នានឹងតាំងខ្លួនឲ្យបានសុខស្រួលផ្លូវទូលាយ ដែលហៅថាជាអ្នកយោងខ្លួនរួចនោះ ត្រូវតែមានការរក្សាខ្លួនទុកឲ្យល្អ វៀរចាកអបាយមុខ ដែលជាផ្លូវនាំឲ្យវិនាសចេញឲ្យ

ស្រឡះ គឺជាអ្នកមិនលេងល្បែងភ្នាល់ ១, មិនផឹកទឹកស្រវឹងគឺ សុរាទឹងមេរ័យ ១, មិនលោភខ្ជាំងក្នុងផ្លូវមាតុគ្រាម ១. មិនសេពគប់មនុស្សពាលយកជាមិត្ត ១ ។

ការចិញ្ចឹមជីវិតសមគួរ ដែលត្រូវតាមលក្ខណៈសម្បត្តិ ដូចពោលមកនេះ ហៅថា សមជីវិតា ។

ព្រះពុទ្ធសាសនា ជាសាសនាប្រាប់ប្រយោជន៍ទាំងផ្លូវបច្ចុប្បន្ន និងបរលោក ដើម្បីឲ្យប្រជាជនទទួលអំណោយសេចក្តីសុខ ចំរើនសមដូចសេចក្តីប្រាថ្នា, មិនមែនពន្យល់បំភ័ន្តចំពោះតែប្រយោជន៍ទៅបរលោកតែម្យ៉ាង ឬមិនមែនបណ្តោយឲ្យដេកចាំព្រេងសំណាងនោះឡើយ ។

ព្រះពុទ្ធសាសនាសម្បូណ៌ពាក្យប្រៀនប្រដៅប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ឲ្យប្រជាជនសិក្សាប្រតិបត្តិតាមនោះជាច្រើនន័យណាស់ មិនមែនខ្វះទេ គឺជាពាក្យដំបូន្មានរំលឹកដាស់តឿននេះ មានក្នុងគម្ពីរព្រះពុទ្ធសាសនាជាច្រើនណាស់, មិនមែនព្រះពុទ្ធសាសនានាំឲ្យខ្ជិលច្រអូសឲ្យរង់ចាំផលទៅអនាគតតែម្យ៉ាងនោះឡើយ ។

ពណ៌នាធម្មកថាអំពីប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាង ក៏សូមសន្មតបញ្ចប់តែប៉ុណ្ណេះ ។

សូមជូនពរចំពោះអស់លោកអ្នកស្តាប់ទាំងឡាយ ឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលគ្រប់ៗគ្នា ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

" សព្វសត្វទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខ, សូមឲ្យជាអ្នកឥតទុក្ខទៅ ! ដែលដល់នូវភ័យ, សូមឲ្យជាអ្នកឥតភ័យទៅ ! ដែលដល់នូវសេចក្តីសោក សូមឲ្យជាអ្នកបាត់សោកទៅ ! "

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា ។

" ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយអ្នកនៅកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើន និងសន្តិភាព កុំបីឃ្លាតក្លាយទៅជាប្រការៈដទៃឡើយ ! " ។

## ពិធីទទួលសម្ដេចសង្ឃនាយក

នៅវត្តដំណាក់ សៀមរាប

# ព្រះមហា កែ - អឿន រៀបរៀង

ដោយបានទទួលថេរបញ្ជាការ នៃព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណ

---

## ថ្ងៃទី ២ គឺថ្ងៃអង្គារ ៥ រោចខែអស្សុជ

ម៉ោង ៨ ព្រឹក ហែកឋិនពត្ន ក្រុងសៀមរាប

ម៉ោង ៩ ពួកពុទ្ធបរិស័ទជាច្រើនជួបជុំនៅទីព្រះវិហារ; ផ្នែកខាងបព្វជិតមានព្រះសង្ឃក្នុងវត្តដំណាក់ សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក ជួន - ណាត និងព្រះតេជព្រះគុណព្រះពោធិវង្សហួត - តាត ជាអធិបតី, ផ្នែកគ្រហស្ថពួកពុទ្ធបរិស័ទក្រុងភ្នំពេញ និងពួកពុទ្ធបរិស័ទខេត្តសៀមរាប មានឧកញ៉ាកជប្រតិក្ខ ហ៊ុយ - ម៉ោង និងលោកវរសេនីយត្រី ឈួនមុម្ពុនពេជ្រ ជាអធិបតី, វេរកឋិនថ្វាយព្រះសង្ឃ មុននឹងវេរកឋិនមានថ្លែងសុន្ទរកថាឆ្លើយឆ្លងទៅវិញទៅមក សុន្ទរកថាខាងពុទ្ធបរិស័ទភ្នំពេញដូចមានសេចក្ដីតទៅនេះ ៖

សម្ដេច !

ព្រះតេជព្រះគុណព្រះពោធិវង្ស !

ព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ !

ព្រះករុណាគ្រប់ព្រះអង្គ !

ព្រះតេជព្រះគុណព្រះរាជប្រតិភូ !

លោកវរសេនីយត្រី កងឯកទេសខ្មែរ !

លោកសប្បុរសទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំបាទ ជាតំណាងឧបាសក សួស-ឆេង ឧបាសិកា ហ៊ង-គីម ម្ចាស់កឋិនទាននេះ សូមថ្លែងសេចក្ដីត្រេកអរចំពោះសម្ដេចព្រះតេជព្រះគុណដែលបាននិមន្តអញ្ជើញមកជាកិត្តិយស និងចំពោះលោកអ្នកសប្បុរសទាំងឡាយ ដែលបានហែហមកឋិនទានមកដល់ទីនេះ ព្រមទាំងលោកសប្បុរសទាំងឡាយជាអ្នកជើងវត្តនេះ ការនិមន្តនិងអញ្ជើញនេះ នាំឲ្យបុណ្យកឋិនមានសភាពរុងរឿងជ្រះថ្លា នាំឲ្យកើតសទ្ធាមុះមុតកើតបីតិសោមនស្សដ៏ក្រៃលែង ខ្ញុំព្រះករុណា ខ្ញុំបាទ សូមត្រាទុកនូវគុណូបការដ៏ប្រសើរនេះទុកក្នុងដួងចិត្ត ជាអនុស្សរណកិច្ច ធ្ងន់ឧបការព្រះតេជព្រះគុណ ៗ ដទៃពីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអភ័យទោស សូមអនុញ្ញាតឲ្យរៀបរាប់ដំណើរដើមទង បុណ្យកឋិនទាននេះប្រគេន និងជូនជាសណ្ដាប់ដូចសេចក្ដីតទៅនេះ ៗ

សម្ដេច! ព្រះតេជព្រះគុណ! បុណ្យកឋិននេះ គួរឲ្យលោកសប្បុរសទាំងឡាយឆ្ងល់ដែរ ខ្ញុំព្រះករុណា ខ្ញុំបាទ នៅក្រុងភ្នំពេញ ឆ្ងាយពីវត្តនេះរាប់រយគីឡូម៉ែត្រ ដូចម្ដេចបានជាបបួលគ្នាហែមកវត្តនេះ ដំណើរនេះមកពីខ្ញុំព្រះករុណា ខ្ញុំបាទ ជាអ្នករកទទួលទាន តែងទៅមកកាន់ទីនេះរឿយៗ

បានជាចូលមកគោរពនមស្សការព្រះរតនត្រ័យ បានឃើញវត្តនេះមានសេចក្តីរុងរឿង មានកុដិសាលាល្អ មានទីសមាធិរហោឋាន មានភិក្ខុសាមណេរកុះករអាស្រ័យនៅរៀនសូត្រ ក៏កើតសេចក្តីជ្រះថ្លាទឹកមមៃនៅក្នុងចិត្តថា: គួរអាត្មាអញបំពេញកុសលអ្វីហ្ន៎ ទុកជាបុញ្ញនិធិក្នុងវត្តនេះ ។ ជ្រើសរើសកុសលទាំងពួងទៅ ឃើញថាគួរនាំកឋិនមកវេរថ្វាយភិក្ខុសង្ឃដែលគង់ចាំវស្សាអស់កំឡុងត្រៃមាសក្នុងវត្តនេះ ព្រោះស្រុកនេះ មិនដែលមានអ្នកកំពេញហែកឋិនមកទេ ទើបបានហែកឋិនមកនេះ កឋិននេះជាកុសលមួយប្រសើរណាស់ ព្រោះនឹងកើតជាអបរាបរចេតនាកុសលចិត្តជាប់នៅក្នុងចិត្តមិនភ្លេច អស់កាលយូរអង្វែង កើតមកពីដំណើរផ្លូវឆ្ងាយក្រែងនឹងមានលោកសប្បុរសណាមួយធ្វើបាន ។

មួយទៀត កាលនេះ ជាកាលទាន គួរតែបំពេញនឹងទានពុំបាន នឹងបានជាទក្ខិណានុប្បទានកិច្ចសង្គ្រោះដល់បុព្វការីបុគ្គលទាំងឡាយមានមាតាបិតាជាដើម នឹងជាកិច្ចធ្វើអាយុសង្ខារឲ្យបានញយៗព្រោះជីវិតសត្វមិនទៀងទាត់ ។ ខ្ញុំព្រះករុណា ខ្ញុំបាទ ក៏ធ្លាប់បំពេញកុសលរៀងរាល់ឆ្នាំ មានធ្វើបុណ្យកឋិននឹងហែផ្កានឹងកុសលឯទៀតច្រើនប្រការ តាមសណ្តាប់អ្នកកាន់ព្រះពុទ្ធសាសនា ដើម្បីជួយកសាងសេនាសនៈក្នុងវត្តអារាមផ្សេងៗ ជាច្រើនវត្ត ព្រោះបានធ្លាប់ស្តាប់ធម្មទេសនាលោកអ្នកប្រាជ្ញ លោកប្រដៅថា: គួរបំពេញកុសលទុក

ជាបុញ្ញនិធិឲ្យបានរឿយៗ កុសលនេះហើយជាអរិយទ្រព្យឲ្យយើងពិតៗ ប្រាកដ ហើយជាឧបនិស្ស័យជួយបន្ទំបារមីយើងឲ្យចាស់ក្លា ឆាប់បាន ត្រាស់ដឹងមគ្គផលនិព្វាន កន្លងផុតសេចក្តីទុក្ខគ្រប់ប្រការក្នុងសង្សារ-វដ្តនេះ ។ ទ្រព្យសម្បត្តិនេះ បើចេះគិតលៃលក ទើបបានជាប្រយោជន៍ ។ បើមិនចេះលៃលកទេ ក៏អសារបង់ឥតអំពើ ហើយត្រឡប់ជាមានទោស ព័ន្ធខ្លួននាំឲ្យអន្តរាយកំណើត ដូចអានន្ទសេដ្ឋីទៅកើតជាកូនចណ្ឌាល រូបអាក្រក់ដូចបិសាច កាន់អំបែងដើរសុំទានគេ រហូតដល់ផ្ទះខ្លួនឯង តែកូនខ្លួនឯង ឈ្មោះមូលសិរីស្មានថាជាខ្មោច វាយសម្លាប់យកទៅ បោះចោលលើគំនរសម្រាម ។ ទ្រព្យសម្បត្តិដែលយើងខំប្រឹងរក បានមកនេះ បើមិនបរិភោគខ្លួនឯង នឹងមិនបរិច្ចាគជាសាធារណទានទេ តើមានប្រយោជន៍អ្វី? បើគ្រាន់តែរកយកមកគរទុកច្រើន ដើម្បីឲ្យបាន ឈ្មោះថាជាមហាសេដ្ឋី នោះអ្នកក្រីក្រ ក៏អាចពោលអួតខ្លួនជាមហា សេដ្ឋីបានដែរ ។ ទ្រព្យសម្បត្តិនេះ កាលរកលំបាកម្តងៗ បានហើយ លំបាករក្សាម្តង វិនាសទៅវិញ ក្តៅក្រហាយចិត្តម្តងទៀត បើដូច្នេះ ទ្រព្យសម្បត្តិនេះ មានប្រយោជន៍ដូចម្តេចខ្លះ? ។ ព្រោះហេតុនេះហើយ បានជាលោកពោលថា អ្នកប្រាជ្ញចាក់សេចក្តីកំណាញ់ គួរបំពេញ ទានឲ្យបានរឿយៗ ធ្វើបុណ្យញយៗ បានបុណ្យញយៗ ធ្វើឲ្យស្ទួន អ្នកស្រុកល្អញយៗ ព្រោះទ្រព្យដែលបំពេញទានជាកុសល ទើប

ឈ្មោះថាជាទីពឹងរបស់យើងមែនទែន ។ អាស្រ័យហេតុដូចបានពោលមកខ្លះៗនេះ ជាដើមទើបកើតជាកឋិនទានក្នុងថ្ងៃនេះឡើង ។ ការហែកឋិនមកនេះ មានហេតុលំបាកច្រើនប្រការណាស់ ណាមួយផ្លូវឆ្ងាយដាច់ស្រយាល ណាមួយប្រកបដោយភ័យច្រើនប្រការ ជាហេតុនាំមិនឲ្យមានលោកសប្បុរសជនមកជួយហែហម តែដោយសេចក្ដីខ្លាំងជាកម្លាំង ខ្ញុំព្រះករុណា ខ្ញុំបាទ ភ្លេចនឹកដល់សេចក្ដីលំបាក នឹងភ័យនេះអស់ ទោះជាយ៉ាងណាក៏ចេះតែខំប្រឹងហែមកវេរថ្វាយព្រះសង្ឃឲ្យបានសម្រេចដូចបំណង ។ ឥឡូវនេះគោលបំណងបានសម្រេចហើយ កឋិនទានយើងបានហែមកដម្កល់កណ្ដាលជំនុំសង្ឃដោយសុវត្ថិភាពហើយ ខ្ញុំព្រះករុណា ខ្ញុំបាទ មានសេចក្ដីត្រេកអរយ៉ាងក្រៃលែង រកអ្វីប្រៀបមិនបាន យើងខ្ញុំនឹងវេរថ្វាយព្រះសង្ឃក្នុងពេលនេះ មុនវេរ ខ្ញុំសូមជូនកុសលដែលកើតពីកឋិនទាននេះ ។

ទី ១ ចំពោះបុព្វការីបុគ្គលមានមាតាបិតាជាដើមរបស់យើងខ្ញុំគ្រប់គ្នា ទោះអស់លោកទាំងនោះមានជីវិតរស់នៅក្ដី លះបង់លោកនេះទៅកាន់បរលោកហើយក្ដី សូមឲ្យបានទទួលឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ ទាំងនាលោកនេះ នឹងបរលោកកុំបីខានឡើយ ។

ទី ២ សូមជូនកុសលដ៏ប្រសើរនេះ ចំពោះសប្បុរសញាតិមិត្តដែលបានចូលចាប់កុសល ហើយបានជួយហែហមកឋិនទាននេះរហូតមកដល់

វត្តនេះ នឹងចំពោះលោកសប្បុរសទាំងឡាយក្នុងទីនេះ ដែលបាន អញ្ជើញមកជួយអនុមោទនា ដោយកុសលចេតនា នាំឲ្យកឋិនទាននេះ រុងរឿងព្រះថា សូមលោកសប្បុរសទាំងឡាយគ្រប់រូប បានទទួល កុសលកសិដ្ឋខ្ពង់ខ្ពស់ ឲ្យបានសម្រេចសម្បត្តិទាំង ៣ ប្រការ គឺសម្បត្តិ មនុស្ស សម្បត្តិទេវតា នឹងសម្បត្តិព្រះនិព្វានកុំបីឃ្លាត ។

ទី ៣ សូមជូនកុសលដល់ពួកទេវបុត្រទេវតាក្នុងដែនកោដិចក្រ-វាឡ សូមឲ្យបានបុញ្ញភាគក្នុងកឋិនទាននេះស្មើភាគគ្នានឹងយើងខ្ញុំ ដោយ អំណាចបុញ្ញភាគនេះ សូមឲ្យទេវបុត្រទេវតាទាំងឡាយនោះៗ បាន សម្រេចសម្បត្តិទិព្វដ៏វិសេសជាតិយោភាព សមតាមសេចក្ដីប្រាថ្នា ហើយសូមជួយអភិបាលថែរក្សាអស់លោកសប្បុរសទាំងឡាយ ឲ្យតាំង នៅក្នុងសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ប្រការ ព្រមទាំងការពារឧប-ទ្រពចង្រៃ សត្រូវពេតាព្យាធិ ឲ្យបវៀសចៀសចេញឆ្ងាយទៅ កុំបី បៀតបៀនបានឡើយ ។

ទី ៤ – សូមជូនកុសលដល់អស់លោកដែលជួយយានជំនិះក្នុងការ ហែហមកឋិននេះ គឺ:

ឧបាសក ប៊ុន - តេង ឧបាសិកា រួច - ម៉េង

– គី - សេង – ណៃ - សឹម

– វ៉េង - យ៉ន – ណៃ - ហោ

— គីវ៉ើង - យ៉េត — គិម - ឆេង

— ប៉ាវ - ផន — ឈាង គាត

— ឃាង - ហៀត — សុខ - ហេង

— ណៃ - សឿន

— អ៊ីវ - ហៀក

បើមានសេចក្តីប្រាថ្នាយ៉ាងណា សូមឲ្យបានសម្រេចតាមសេចក្តីប្រាថ្នាកុំបីអាក់ខាន ៗ

ទីបំផុត សូមត្រេកអរចំពោះបដិសណ្ឋារកិច្ចរៀបចំទទួលយើងខ្ញុំព្រះករុណា ខ្ញុំបាទ ដោយបណ្ឌិតភោជនីយាហារ នឹងទីសំណាក់អាស្រ័យដ៏ប្រសើរនៃព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យ នឹងអស់លោកសប្បុរសជើងវត្តទាំងអស់ យើងខ្ញុំព្រះករុណា ខ្ញុំបាទ សូមកត់ត្រានូវបដិសណ្ឋារកិច្ចនេះ ទុកជាអនុស្សាវរីយ៍ដ៏ប្រសើរក្នុងដួងចិត្តយើងគ្រប់គ្នារហូតកល្បាវសាន ៗ បើសេចក្តីប្រកាសខ្ញុំព្រះករុណា ខ្ញុំបាទនេះសមតាមសេចក្តីប្រាថ្នាអស់លោកសប្បុរសទាំងឡាយហើយ សូមអស់លោកសប្បុរសទាំងឡាយអនុមោទនាថា សាធុ ឲ្យព្រមៗគ្នាផង ហោង ៗ

លុះចប់ហើយ ឧបាសកឧង្គប៊ុនឡុងជាតំណាងពុទ្ធបរិស័ទវត្តតំណាក់ថ្លែងសុន្ទរកថាតបទៅវិញដូចមានសេចក្តីតទៅនេះៈ-

សូមថ្វាយបង្គំចំពោះសម្ដេច !

សូមថ្វាយបង្គំចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស ព្រមទាំងព្រះថេរានុត្ថេរៈ ទាំងឡាយដោយគោរព ;

សូមប្រណិប័តន៍ព្រះតេជព្រះគុណព្រះរាជប្រតិភូ ខែត្រសៀមរាប !

សូមប្រណិបតន៍ព្រះតេជព្រះគុណវរសេនីយត្រី ( ឯកទេស ) នឹងអស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ មានលោកស្នួស-ធេង ខុណ្ឌ·សិកា ភ៉ីង-គីម ជាដើម ដែលជាសាមីកុសលបុណ្យកឋិននេះ ដោយគារវភាព !

កិត្តិយសដ៏ប្រសើរកើតឡើងយ៉ាងអស្ចារ្យ ដល់ព្រះពុទ្ធសាសនានៅនាវត្តដំណាក់ក្នុងថ្ងៃនេះ នាំឲ្យយើងខ្ញុំអត់ទ្រាំពុំបាន សូមសរសើរដល់សទ្ធាបញ្ញានឹងទឹកចិត្តដ៏ក្លាហានរបស់លោកជាទានសាមី ទាំងប្រុសស្រីដែលខំបបួលញាតិមិត្រទាំងជិតឆ្ងាយ ឲ្យជួយខ្វល់ខ្វាយហែហមអមអង្គព្រះកឋិនមកកាន់ផ្លូវឆ្ងាយដាច់ស្រយាលចំនួន ៣១៤ គីឡូម៉ែត្រយ៉ាងនេះ ភ្លេចគិតពីលំបាកនឿយនឹងគ្រោះថ្នាក់តាមផ្លូវទៅមក ភ្លេចគិតពីសេចក្ដីដាច់ខាតធនធានតិចច្រើនសោះឡើយ ; ហើយបានទាំងជួយនិមន្តសម្ដេចព្រះសង្ឃនាយកនឹងព្រះតេជព្រះគុណព្រះពោធិវង្ស មកឲ្យទានធម៌ទេសនាដល់យើងខ្ញុំគ្រប់គ្នានៅទីនេះស្ដាប់ទៀតផង ។

លោក ស្នួស-ធេង . . . . !

ចូរលោកក្រឡេកភ្នែកមើលចុះ •វត្តដំណាក់នេះ កាលលោកចូលមកឃើញពីដាន់មុន មិនទាន់ដឹងខ្លួនថាលោកនាំមេបុណ្យធំៗ ជាអស្ចារ្យយ៉ាងនេះមកទេ លុះដឹងពេលណា ក៏សម្អាតកាយា ហើយប្រដាប់ដោយគ្រឿងលំអប្លែកៗ រង់ចាំទទួលអនុមោទនាមេបុណ្យរបស់លោក ។ យើងខ្ញុំសូមឲ្យឈ្មោះថា មេបុណ្យ ព្រោះបុណ្យកឋិននេះធំប្លែក ហើយចំឡែកអំពីកឋិនគេតែងធ្វើធម្មតា នាំឲ្យមានផ្កាដៃច្រើនជាអនេក ដែលកើតកូនចួនជាចៅបុណ្យតៗ ទៅទៀត ដោយសារលោកនាំមេបុណ្យធំមកផ្សាយបំភណ្ឌាលទីក្រុងសៀមរាបនេះ ។

លោកឃើញស្រាប់ហើយ ! ពួកពុទ្ធបរិសទ្យទាំងគ្រហស្ថទាំងបព្វជិត ដែលចូលមកម៉ីរគ្រៀបត្រាអង្គុយខ្ទះ ឈរខ្ទះនេះ សុទ្ធតែនៅវត្តនៅភូមិ-ស្រុកដទៃៗ ពីគ្នាទេ ប៉ុន្តែភាក់ផ្អើលភ្ញាក់ខ្លួនមកច្រើនគ្រឹកគគ្រេងនេះ ដោយសារពុសន្ទឹកបុណ្យធំជាខ្លាំងរបស់លោកទេ ដែលហែកឋិនទាន ហើយបេះនិមន្តយកសម្តេចនឹងព្រះតេជព្រះគុណព្រះពោធិវង្សបានមកសំដែងធម៌ទេសនា ! ។

ដោយមានសង្ឃឹមជាមាំថា: សម្តេចទើបនឹងត្រឡប់មកពីលង្កាទ្វីប ហើយបាននិមន្តទៅទតឃើញកន្លែងអស្ចារ្យ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់គង់ត្រាស់ ហើយនិព្វានទៅ នៅសល់តែបូជនីយដ្ឋាន មានដើមពោធិ-ព្រឹក្សជាដើមនោះនឹងតំណាលប្រាប់ផង; លោកដាបស្រាប់ហើយ នាយ

ពាណិជគឺពួកឈ្មួញនានា ដែលនាំយកភារៈមានខ្លឹមសារទៅជួញនោះ ទោះបីនាំទៅតាមផ្លូវទឹកដោយទូកឬសំពៅក្ដី ឬក៏នាំទៅតាមផ្លូវគោកដោយរទេះក្ដី ក៏ប្រយោជន៍ដើម្បីតែចំណេញម្យ៉ាងប៉ុណ្ណោះ ។

ឯជំនួញសាសនារបស់លោកនេះក៏ដូចគ្នា ព្រោះថាលោកចំនាំអដ្ឋកថិនទាន និងនិមន្តធម្មថិកយ៉ាងឯកៗ មកដាក់ទានធម៌ ក៏ប្រយោជន៍ដើម្បីយកតែបុណ្យម្យ៉ាង គ្មានគិតយកផលប្រយោជន៍អ្វីដទៃទៀតឡើយ; ជំនួញបុណ្យនេះខ្ញុំយល់ថាចំណេញហើយ ។ ដោយមានពុទ្ធបរិស័ទជាច្រើននាក់ ស្ម័គ្រចិត្តស្រឡាញ់សាសនាជ្រះថ្លានោះ ។

សូមផ្ដាក់ឈ្មោះលោកព្រមទាំងភរិយា ភ្ជាប់ក្នុងដួងហឫទ័យគ្រប់ៗគ្នា ទុកជាអនុស្សាវរីយ៍ គឺទុកជាទីរលឹកមិនភ្លេចឡើយ ។ ដូចរុក្ខជាតិវល្លិជាតិ នៅចុងគិម្ហរដូវដែលត្រូវទឹកភ្លៀងធ្លាក់ចុះមក ក៏ដុះលូតលាស់ស្លឹកខៀវខ្ចីស្រស់យ៉ាងណា? ពុទ្ធមាមកៈពុទ្ធមាមកានៅនាទីនេះ ក៏មុខជានឹងមានសទ្ធាលូតលាស់ដុះដាលឡើងយ៉ាងនោះដែរ; ដោយសារតែទឹកភ្លៀងគោលគឺព្រះធម៌ទេសនា ដែលហូរចេញអំពីព្រះឱស្ឋសម្ដេចមិនខាន ទោះបីយូរនាប់ ដោយស្មានមើលតាមកាលវេលាកន្លងទៅ ២០ ឆ្នាំហើយ មកដល់សព្វថ្ងៃនេះ ឃើញថាចំរើនដោយការរៀនសូត្រហូតដល់សេចក្ដីប្រតិបត្តិប្លែកជាងមុនច្រើនណាស់ទៅហើយ គួរឲ្យសង្ឃឹមថាពីពេលនេះតទៅ មុខជានឹងមានការចំរើនលឿនច្រើនជាងមុនជានិយ្យាភាព ដោយ

សារបានខេមរជនទាំងក្មេងចាស់ ទាំងនាម៉ឺន-រាស្ត្រ បេះស្រឡាញ់សាសនារបស់ជាតិ ចូលខ្លួនមកជួយឧបត្ថម្ភគាំទ្រជ្រោមជ្រែង បីពស្លុយទ្រទ្រង់ស្មើរតែនឹងគ្រប់គ្នា ។

នៅទីបំផុតនេះ យើងខ្ញុំសូមអរគុណដ៏ធំក្រៃលែង ចំពោះព្រះតេជព្រះគុណព្រះរាជប្រតិភូខេត្ត និងព្រះតេជព្រះគុណវិសេសនិយត្រៃ (ឯកទេស) និងអស់លោក-អ្នកសប្បុរសទាំងឡាយដែលបានផ្ញើកឋិនហែមកមានលោក សួស-ធេងជាដើម ព្រមទាំងអស់លោកទាំងឡាយដែលបានជួយខ្វល់ខ្វាយរៀបចំទទួលបុណ្យកឋិននេះផង ។

សូមឲ្យលោកបានប្រកបដោយសេចក្ដីសុខ · ចំរើន គ្រប់ៗ គ្នាទៅហោង ។

ស្វស្ដី !!! ជយោព្រះពុទ្ធសាសនា

លុះចប់សុន្ទរកថាទាំងពីរហើយវេរកឋិនថ្វាយព្រះសង្ឃសម្រេចកិច្ចៗ

ម៉ោង ៩ យប់និមន្តសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក សំដែងធម៌ទេសនាៗ នោះសម្ដេចទ្រង់សំដែងអំពីប្រវត្តិព្រះពុទ្ធសាសនាក្នុងស្រុកខ្មែរ និងសំដែងអំពីដែលសម្ដេចទ្រង់និមន្តទៅកាន់លង្កាទ្វីប និងប្រទេសភូមា ព្រះសទ្ធម្មទេសនានោះជាទីពីរោះជាប់ចិត្តដក់នៅក្នុងហទយវត្ថុនៃពុទ្ធបរិសទ្យគ្រប់ៗរូប! ពុទ្ធបរិសទ្យខ្លះលាន់មាត់ថា "ពីរោះអ្ហ៎ម៉ែះហ្ន៎ ! អើនេះ ហៅពេញជាពីរោះ" ចំនួន ៤ ម៉ោងកន្លះទើបចប់ ។

លុះចប់ធម៌ទេសនាហើយ លោកវរសេនីយ៍ត្រីថ្លែងទទួលអំណរ ធម្មទេសនាស្តេច ចំនួនកន្លះម៉ោង និងបាត់ការឲ្យកងឯកទេសសំដែងនូវ ភ្លេងជាតិ និងកំរង់តទៅទៀត ដរាបដល់ម៉ោង ២ ទើបឈប់ ។

បុណ្យក្នុងថ្ងៃត្រៀមកបក្នុងពេលនេះ ប្រសើររុងរឿងអស្ចារ្យជាង កាលណាៗទៅទៀត ព្រោះពុទ្ធបរិស័ទដែលមកពីក្រុងភ្នំពេញ ១២០ រថយន្ត និងពុទ្ធបរិស័ទក្នុងថ្ងៃត្រៀមកប ដែលមកពីទិសនានា ច្រើន មិនកុះករណាស់ណាន់តាន់តាប់ ពេញពោរគ្រប់ដំណាក់ ស្ទើរតែដើរចៀស គ្នាពុំរួច ទាំងបព្វជិតទាំងគ្រហស្ថ ។

ដោយតេជានុភាពនៃកុសលពលីក្នុងពេលនេះ យើងខ្ញុំព្រះអង្គសូមផ្ទង់ ហត្ថាដាក់លើសិរសា ឧទ្ទិសបង្អោនថ្វាយចំពោះព្រះបរមមហាក្សត្រិយ៍ ព្រមទាំងព្រះរាជវង្សានុវង្ស សូមឲ្យទ្រង់គង់នៅក្នុងព្រះសិរីរាជសម្បត្តិ ខាត់កយាជាសុខសាន្ត សម្រាន្តក្នុងព្រះកាយពល ដើម្បីសម្រក់ព្រះធារ គឺព្រះមេត្តាព្រហ្មវិហារគ្របដណ្តប់លើប្រជាជនក្នុងកម្ពុជរដ្ឋ កុំបីមាន ឧបស័គ្គមករាំងព្រះរាជហឫទ័យទ្រង់បានឡើយ ។

ម្យ៉ាងទៀត សូមសំបួង សំរូងឲ្យប្រទេសកម្ពុជា ប្រកបដោយ សន្តិសុខ និងសម្បទា ៣ ប្រការ គឺ :

១ – មុនិសម្បទា សូមឲ្យសម្បូណ៌ដោយអ្នកប្រាជ្ញរាជបណ្ឌិតក្នុង ផ្លូវលោកផ្លូវធម៌ ;

២ – ភោគសម្បទា  សូមឲ្យសម្បូណ៌ដោយភោគសម្បត្តិ ;

៣– សាមគ្គីសម្បទា  សូមឲ្យសម្បូណ៌ដោយសាមគ្គីធម៌  ទាំងផ្លូវលោកផ្លូវធម៌ ។

ដើម្បីឲ្យសក្តិសមតាមឋានៈជាប្រទេសឯករាជ្យ ១ទៀត, សូមឲ្យប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូល ប្រកបដោយសេចក្តីសុខសេចក្តីចំរើន អស់កាលជានិរន្តរ៍តរៀងទៅហោង ។

# អនុសំវច្ឆរៈមហាសន្និបាត ទី ៧
# នៃមន្ត្រីសង្ឃ ក្នុងព្រះរាជអាណាចក្រ កម្ពុជា

របស់

# ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

កាលនៅថ្ងៃទី ២៣ ខែមករា ឆ្នាំ ១៩៥១ មន្ត្រីសង្ឃទាំងឡាយក្នុងព្រះរាជអាណាចក្រ បានធ្វើពិធីអនុសំវច្ឆរៈមហាសន្និបាតឆ្នាំ ទី ៧ នៅវត្តព្រះកែវមរកត ក្រុងភ្នំពេញ ។ ក្នុងវេលាម៉ោង ៩ កន្លះព្រឹកនៃថ្ងៃនោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះពស្ត្រតាមទំនៀម បានទ្រង់ស្តេចយាងទៅជាព្រះរាជាធិបតីក្នុងឱកាសពិធីមហាសន្និបាតនេះ ។ កាលព្រះបរមមហាក្សត្រិយ៍ស្តេចដោយរថយន្តដល់ច្រកខាងមុខនៃព្រះអារាម, មានក្រុមទាហានរក្សាព្រះអង្គ និងក្រុមភ្លេងព្រះរាជទ្រព្យធ្វើគារវកិច្ចតាមទំនៀម ។ នៅទីនោះព្រះអង្គក្រុមហ្លួង នាយករដ្ឋមន្ត្រី, ឯកឧត្តម អ៊ុំ-ស៊ុន-ឈាង ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, សមាជិក-រដ្ឋាភិបាលជាច្រើននាក់, ឯកឧត្តម សាន-យុន ជាចៅហ្វាយក្រុង និងឥស្សរជនដទៃទៀតជាច្រើនក៏បានចាំហែព្រះរាជា ។ តពីច្រកខាងមុខនៃព្រះអារាមទៅ ព្រះករុណាស្តេចដោយព្រះបាទ ឆ្ពោះទៅកាន់ព្រះធម្មមន្ទីរ ដែលមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ, សម្តេច

ព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សម្តេចព្រះធម្មលិខិត ខុត្តមប្រក្យ ល្វីឯម ហើយនឹងមន្ត្រីសង្ឃគ្រប់ព្រះរាជាណាចក្រទាំងមូលដែលមានចំនួន ១៥០ អង្គ បាននិមន្តទៅជួបជុំយ៉ាងស្មោះសរគ្រប់ទីនោះ ។ ក្រៅពីមន្ត្រីសង្ឃទាំងនេះ ឃើញមានចៅអធិការមកពីខេត្តក្រៅ ហើយនឹងភិក្ខុសាមណេរដទៃទៀតចំនួនជាង ៥០០ អង្គ គង់ត្រៀបត្រាពេញទាំងវិហារខាងត្បូងជាមួយពួកអាចារ្យវត្តនឹងឧបាសកឧបាសិកាទាំងគ្រប់ទីក្រុងនឹងខេត្តក្រៅ ជាច្រើនរយនាក់ទៀត ដើម្បីរង់ចាំស្តាប់ព្រះបរមរាជឱង្ការនៃព្រះរាជបន្ទូលស្តីសីហនាទ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលមានឧត្តមសេចក្តីពេញព្រះសូរសៀង ។

ពិធីនេះបានចាប់ផ្តើមឡើង ក្រោយដែលមានការបង្គំគ្រូលថ្វាយព្រះបិតរនៅចេតិយខាងមុខព្រះវិហារ ។ ព្រះរាជាលុះទ្រង់ធ្វើនមស្ការចំពោះព្រះសង្ឃទាំងឡាយរួចហើយ ទើបទ្រង់ថ្លែងព្រះរាជសុន្ទរកថាមួយពន្យល់អំពីរបបរាជនៃឯករាជ្យប្រទេសយើង ដែលយើងសូមយកមកផ្សាយជូនទាំងមូលដូចតទៅនេះ —

## ព្រះរាជសុន្ទរកថា

(មហាសន្និបាតប្រជុំលោកគ្រូមេគណជំនុំរាជាគណៈ)

នៅឱកាសដែលលោកគ្រូនិមន្តមកប្រជុំអនុសំវច្ឆរៈមហាសន្និបាតសំរាប់ឆ្នាំនេះ, ខ្ញុំករុណាសូមថ្វាយបង្គំលោកគ្រូដោយគោរពជាបំផុត

ហើយសូមថ្លែងសេចក្ដីសោមនស្សរីករាយនៃខ្ញុំករុណា ដោយឃើញលោកគ្រូសុខសប្បាយគ្រប់ព្រះអង្គដូចកាលមុន ហើយនិមន្តមកពីខេត្តក្រៅជាច្រើនព្រះអង្គផង ។

ខ្ញុំករុណាដឹងណាស់ អំពីដំណើរដែលអាណាខេត្តយើងនិងអ្នកស្រុក ទាំងបព្វជិតនិងគហស្ថនៅក្នុងអាណាខេត្តទាំងប៉ុន្មាន រងទុក្ខវេទនាក្នុងសម័យនេះ ដោយអសន្តិសុខនិងវិនាសកម្មច្រើន មកពីអសន្តិសុខនេះយ៉ាងណា ។ ដោយហេតុនេះ បានជាខ្ញុំករុណាគិតជាដរាបទៅដល់ស្រុកស្រែចំការរបស់យើងពុំដែលអាក់ខាន, បានជារដ្ឋាភិបាលនិងខ្ញុំករុណា ខំប្រឹងខ្នះខ្នែងជាបំផុត ដើម្បីបំរើប្រទេសធ្វើឲ្យរួចរួតពីទុក្ខវេទនាឲ្យខាងតែបានតាមដែលធ្វើទៅកើត ។

ខ្ញុំករុណាដឹងថា មិនគួរនឹងអធិប្បាយអំពីការណ៍នយោបាយពិតលោកគ្រូទេ តែខ្ញុំករុណាដឹងដែរ អំពីការដែលលោកគ្រូយកព្រះទ័យទុកដាក់យ៉ាងណា នឹងសាសនាប្រទេសយើង ដែលមានព្រះពុទ្ធសាសនាជាទីពឹងពំនាក់ដ៏ខ្ពស់ប្រសើរនេះ ។ ដូច្នេះខ្ញុំករុណាត្រូវពិតពុទ្ធដីកាលោកគ្រូជ្រាប អំពីស្ថានការណ៍ប្រទេសយើងដោយសង្ខេប ។

ស្ថានការណ៍នេះ មានអសន្តិសុខរីតរូបគ្របសង្កត់ជុំជិត ។ តើយើងចាត់ការបានសម្រេចអ្វីហើយ ដើម្បីនឹងកំចាត់អសន្តិសុខនោះ ។ យើងដឹងគ្រប់រូបទាំងអស់ថា អ្នកដែលបង្កើតអសន្តិសុខនេះ គឺបង្កើតដោយ

យកនាមឯករាជ្យមកប៉ាំងថា ខ្លួនធ្វើឲ្យបានឯករាជ្យឲ្យប្រទេសកម្ពុជា ។ ខាងវៀតមិញក្ដី ខាងឥស្សរៈក្ដី ពួកដែលតយុទ្ធនឹងបារាំង តយុទ្ធនឹងកងទ័ពរដ្ឋាភិបាលយើង តែងមានពាក្យថា ខ្លួនធ្វើចម្បាំងដើម្បីនឹងដេញបារាំងនេះ ១, ហើយមួយវិញទៀតថា ធ្វើចម្បាំងដើម្បីធ្វើទណ្ឌកម្មអ្នករាជការខ្មែរជាតិដែលខ្លួនប្រកាន់ថាជាអ្នកសមគំនិតនឹងបារាំងនេះ ២ ។

តាំងមកអំពីគិតធ្វើឲ្យលែងមានវៀងគំនិតគ្នាដូច្នោះទៀត មកអំពីគិតគាំពារសន្តិសុខដែលវិនាសទៅ ដោយពួកអ្នកដែលតាំងខ្លួនថាជាអ្នកបេះស្រឡាញ់ជាតិជាងយើង នេះហើយ បានជាកងការដែលបង្រ្កាបអសន្តិសុខនេះ រដ្ឋាភិបាលនឹងខ្ញុំករុណា បានប្ដេជ្ញាចិត្តគិតសង្រ្គាត ធ្វើឲ្យបានសម្រេចនូវបំណង ១ ជាបឋមហេតុសិន គឺធ្វើឲ្យឯករាជ្យដោយពេញលេញ ។

ឥឡូវនេះ ខ្ញុំករុណា អាចនឹងពិតពុទ្ធដីកាលោកគ្រប់ដោយស្មោះថា បំណងរបស់យើងនេះ បានសម្រេចជិតពេញបំណងហើយ ។ ឯករាជ្យរបស់យើង បានសម្រេចដល់ ៨០ កងភាគរយ ។ ក្រៅអំពីកិច្ចការខាងតុលាការ នឹងកិច្ចការខាងសឹកសង្រ្គាម នោះឯករាជ្យរបស់យើងឥតមានអ្វីជាខបស័គ្គទៀតទេ ។

ឯសន្និសិទនាក្រុងប៉ារីស បានសម្រេចការថា ក្រុមរាជការតាំងប៉ុន្មានដែលនៅខ្វះមិនទាន់បានមកយើង ដើម្បីបំពេញការឯករាជ្យរបស់យើង

ឲ្យពេញលេញឡើង នោះត្រូវផ្ទេរមកឲ្យប្រទេសយើងទៀត មានក្រុមគយ, ក្រុមប្រៃសណីយ៍ និងឃ្លាំងប្រាក់ជាដើម ។ ក្រុមទាំងនេះព្រមទាំងអំណាចចាត់ការក្នុងក្រុមនេះ ត្រូវបានមកយើងពេញអធិបតេយ្យក្នុងដែនប្រទេសយើងទាំងមូល ។ អំពីនេះតទៅ លែងមានក្រុមរាជការរួមទៀតហើយ ក្រុមទាំងនេះត្រូវផ្ទេរឲ្យរដ្ឋនីមួយៗ នៅមានតែក្រុមរាជការរួមគ្នាបីរដ្ឋដែលត្រូវជួបជុំ ជំនុំតែវេលាណាដែលអាណាប្រយោជន៍នៃប្រទេសលាវ, ប្រទេសវៀតណាមនឹងប្រទេសកម្ពុជា មានប្រស្រ័យទាក់ទងនឹងគ្នា; ប្រទេសបារាំងនឹងចូលជំនុំការក្នុងក្រុមកម្មាធិការនេះ បានតែកាលណា ដែលត្រូវមានកិច្ចការពារអាណាប្រយោជន៍ប្រទេសបារាំង ឬអាណាប្រយោជន៍ដែនដីបារាំងខាងនាយសមុទ្រនៅប្របរដ្ឋយើងទាំង ៣ នេះ ។

ជាប្រការដោយឡែក ឃើញនៅមានអង្គការមួយរួមគ្នា គឺវិជ្ជាស្ថានបោះធនប័ត្រ (ក្រដាសប្រាក់) ព្រោះប្រទេសយើងទាំងអស់ ក្នុងដែនឥណ្ឌូចិន មិនទាន់អាចនឹងលែងត្រូវការប្រើប្រាស់ប្រាក់រៀលរបស់យើងបាននៅឡើយ, តែប្រាក់រៀលនេះត្រូវមានរូបប្លែកគ្នា តាមប្រទេសខ្មែរ ប្រទេសវៀតណាម ឬប្រទេសលាវ គឺជាការផ្តើមកិនភាគហិរញ្ញវត្ថុឲ្យប្លែកដាច់ពីគ្នាទៅថ្ងៃមុខ ។

ខាងរបៀបការទូត យើងបានអធិបតេយ្យពេញទីហើយ ។ ដើម្បីឲ្យឯករាជ្យយើងបានពេញលេញឡើង ប្រទេសបារាំងបានទាំងព្រមផាស់សេចក្ដីបញ្ញត្តិមួយ១យ៉ាងសំខាន់កងសន្ធិសញ្ញា ។

អំណើះតទៅ អ្នកការទូតបរទេសត្រូវចូលមកផ្ទាល់ព្រះមហាក្សត្រិយ៍សុំឲ្យទទួលស្គាល់ មិនបាច់ទៅដល់ប្រធានាធិបតីបារាំងឡើយ ។ ព្រះមហាក្សត្រិយ៍ ត្រូវជូនអ្នកការទូតផ្ទាល់ទៅប្រមុខរដ្ឋបរទេស ត្រូវចេញសារតាំងដោយអង្គឯងនឹងឯកឯង គឺចុះហត្ថលេខាតែមួយព្រះអង្គឯង, ពិតមែនតែកងសន្ធិសញ្ញាមានបញ្ញត្តិថា ត្រូវឲ្យមានចុះហត្ថលេខាប្រធា-នាធិបតីបារាំង លើសារតាំងនោះផង ។

អធិបតេយ្យរបស់យើង ខាងសឹកស្រ្គាមនឹងបានមកឯង នៅវេលាណាដែលយើងនឹងដោះស្រាយបញ្ហាវៀតមិញបាន ។

យើងកំពុងខិតខំខ្លាំងណាស់ ដើម្បីនឹងដកកងទ័ពបារាំងបន្តិចម្ដង១ ហើយនឹងពង្រីកអំណាចបញ្ជាការរបស់យើងឱ្យទៅកងដែនប្រទេសយើង ។

កងពលរបស់យើង ដែលមានមកកងឆ្នាំ ១៩៥០ តាំងប៉ុន្មាន ដល់ទៅឆ្នាំ ១៩៥២ នឹងបង្កើតឲ្យមានច្រើនឡើងទ្វេមួយជាពីរ ។

ចំណែកខាងតុលាការ យើងចាំដល់ពេលណាធ្វើខសញ្ញា ឲ្យបានសម្រេចតាមបំណងនៃប្រជាជាតិបាន ទើបនឹងព្រមចុះហត្ថលេខាជាមួយ

ប្រទេសបារាំង, ក្រៅអំពីនេះ អធិបតេយ្យរបស់យើងបានពេញលេញទាំងអស់ហើយ ។

ពួកបុគ្គលិកជាតិបារាំងទាំងប៉ុន្មាន នៅក្រោមបង្គាប់រាជការខ្មែរទាំងអស់ ហើយបានទុកឲ្យនៅធ្វើការចំនួនត្រឹមតែយើងត្រូវការប៉ុណ្ណោះ ឯលោកកុម្មីស្សែរដឺឡារ៉េពុយព្លិក នឹងអ្នកតំណាងរបស់គេទាំងប៉ុន្មាន អំណេះតទៅ មានមុខងារត្រាន់តែជាអ្នកតំណាងប្រទេសបារាំងប៉ុណ្ណោះទេ ឯអ្នកតំណាងនៅខែត្រក្រៅ ដែលហៅថា កុងសីយេរនោះ កាន់ការងារត្រឹមតែជាកុងស៊ុល ។

ខ្ញុំករុណាដឹងថា មានជនរួមជាតិយើងជាច្រើនរូបមិនសប្បាយចិត្ត ដោយឃើញក្រុមរាជការខ្លះ មានបារាំងធ្វើការឬ បារាំងត្រួតត្រា ហើយមន្ទិលថា ក្រែងក្រុមទាំងនោះមិនមែនជារបស់ខ្មែរ ។ គ្មានអ្វីជាឧបសគ្គទេ គឺថាបើមានតម្រិះវិជ្ជាស្មើគ្នា យើងនឹងយកជនរួមជាតិឲ្យកាន់កាប់ទីតំណែងនីមួយៗ ។ ដែលមានទីតំណែងខ្លះ ជាតំណែងតិកនិកត្រូវតែមានបុគ្គលិកប៉ិនប្រសប់ ទើបកាន់កាប់បាន ។ បើយើងដាក់ជនណាដែលមានតម្រិះវិជ្ជាមិនដិតដល់ឲ្យទៅកាន់កាប់តំណែងនោះ របៀបការកងតំណែងនោះនឹងចាត់ការទៅពុំបានស្រួលល្អ នេះឃើញថា ប្រទេសជាតិនឹងការឯករាជ្យនឹងបានផលអាក្រក់ ។

ពួកនិស្សិតជាតិយើង ដែលយើងជួយទំនុកបំរុងពេញទំហឹងនោះ អាចនឹងទទួលការជួសបារាំងបានបន្តិចម្តងៗតាមសញ្ញាប័ត្រ នឹងតាមរបៀបដែលធ្លាប់ប្រសប់ការ ព្រោះដែលនឹងកាន់កាប់ក្រមរាជការនីមួយ ៗ បានស្រួលនោះ លុះត្រាតែធ្លាប់ប្រសប់ការយូរឆ្នាំល្មមផង ទើបបានស្រួល ៗ នៅចុងបង្អស់ គេប្រើនក្កុចថា ក្រមរាជការរបស់យើងទាំងប៉ុន្មាន នោះមានខ្មែរត្រួតត្រាក្តី មានបារាំងត្រួតត្រាក្តី ត្រូវទៀងរដ្ឋមន្ត្រីជាតិយើងទាំងអស់ ៗ

ដូច្នេះ លោកគ្រូគ្រប់ព្រះអង្គ អាចជ្រាបយល់បានថា ឯករាជ្យរបស់យើងមិនមែនមានតែផ្លូវបើកហើយប៉ុណ្ណោះទេ គឺថាបំណងនៃឯករាជ្យរបស់យើងនេះបានសម្រេចពេញលេញ សឹងតែទាំងអស់ទៅហើយថែមទៀត ៗ

តាមយោបល់ខ្ញុំករុណា យល់ឃើញថា អំណឹះតទៅ អស់មានឧបសគ្គអ្វីជាធំដុំមកខាំងយើងទៀត មិនបានឲ្យសម្រេចផលឯករាជ្យពេញលេញនោះឡើយ ៗ ប្រទេសបារាំងបានទាំងទទួលស្គាល់ថា នឹងឲ្យយើងបានឯករាជ្យបរិបូណ៌ ហើយថាគ្មានសុំអ្វីអំពីយើងក្រៅពីសុំឲ្យយើងធ្វើជាសម្ពន្ធមិត្ត ដោយស្មើមុខគ្នានោះទេ ៗ

ឧបសគ្គធំតែមួយ ដែលយើងនៅមាននឹងត្រូវបំបាត់នោះ គឺ អសន្តិសុខ, គឺមហាភ័យនឹងវៀតមិញ នឹងមហាភ័យនឹងលទ្ធិរួមសម្បាប់

(កុម្មុនិស្ត) ។ មហាភ័យនឹងលទ្ធិនេះសម្រាប់ មិនមែនគ្រាន់តែភ័យចំពោះលទ្ធិរាជាធិបតេយ្យប៉ុណ្ណោះទេ គឺភ័យចំពោះសាសនារបស់យើងនឹងចំពោះប្រទេសយើងជាមុនគេ ក្រែងពុំបានគង់នៅឋិតថេរតទៅ ។ ខេមរជាតិច្រើនរូប អាចបានយល់ឃើញច្បាស់អំពីការភ័យនេះស្រាប់ហើយ ។ ពួកឥស្សរៈជាច្រើន ក៏បានយល់ឃើញដូច្នោះដែរ, គឺដោយហេតុនេះហើយបានជាយើងឃើញថា ពួកឥស្សរៈខ្លះ វិលទៅជាមានប្រតិកម្មខ្លាំងនឹងពួកវៀតមិញ ខ្លះទៀតក៏មានបំណងគិតចូលមករួបរួមនឹងរាជការជាតិវិញ ។

ក្រុមឥស្សរៈខ្លះនិយាយថា ចង់ជួយពួតដៃជាមួយរដ្ឋាភិបាល នេះឃើញថាពួកនេះមានចិត្តស្រឡាញ់ជាតិពិតមែន ។ តែខ្ញុំករុណា សូមស្តាយមង្គភាពរបស់ពួកនេះ ក្នុងការដែលចង់ចូលមករួបរួមដូច្នេះណាស់ ។

ខ្លះមានវាចានិយាយ នឹងមានគំនិតគិតថា បើខ្លួននឹងធ្វើកត្តិកាសញ្ញានឹងរដ្ឋាភិបាលពេញមុខពេក នឹងនាំឲ្យប្រជារាស្ត្រលែងមានសេចក្តីទុកចិត្តលើខ្លួន ។ បើដូច្នេះ តើប្រជារាស្ត្រមិនសូវស្មោះត្រង់នឹងរដ្ឋាភិបាលជាតិប៉ុន្មានទេឬ? តាមការពិត គឺមិនមែនសមប្រកបដូច្នោះទេ ។

តាមយោបល់ខ្ញុំករុណា បើពួកឥស្សរៈនេះចង់ធ្វើប្រយោជន៍ឲ្យមាតុភូមិរបស់យើងពិតមែន ត្រូវតែសំដែងឲ្យប្រជារាស្ត្រឃើញថា សម័យនេះមិនគោងបែកសាមគ្គីគ្នាទេ ។ មធ្យោបាយដ៏ប្រពៃ ដែលនឹងធ្វើឲ្យ

ប្រជាពលរដ្ឋ មានសេចក្ដីទុកចិត្តដល់ជាតជាតានៃប្រទេសយើងវិញ គឺត្រូវសំដែងឲ្យប្រជាពលរដ្ឋឃើញថា លែងមានកងទ័ពពីរ គឺកងទ័ពរាជការម្ខាង កងទ័ពឥស្សរៈម្ខាងទៀតហើយ តែមានតែកងទ័ពជាតិមួយប៉ុណ្ណោះ ។ គឺត្រូវសំដែងឲ្យប្រជាពលរដ្ឋឃើញថា គ្មានរាជការ ២ ឬរាជការ ៣ ទេ, តែមានតែរាជការតែមួយ គឺ រាជការដែលចេញអំពីរាជធានីរបស់យើង ។

ខ្ញុំករុណា មានសេចក្ដីសង្ឃឹមថា ពួកឥស្សរៈដែលចេះស្រឡាញ់ជាតិដល់ទៅថ្ងៃណាមួយខាងមុខឆាប់ៗ នេះជាមិនខាន នឹងមានគតិបណ្ឌិតគ្រប់គ្រាន់ នឹងជួយដោះស្រាយទុក្ខឲ្យប្រជាពលរដ្ឋយើងបាន ដោយចូលមករួបរួមនឹងរដ្ឋាភិបាល ដើម្បីនឹងការពារប្រជាពលរដ្ឋយើង ។

បណ្ដាពលរដ្ឋខ្លះ នៅស្រែចំការ កើតសេចក្ដីក្ដៅក្រហាយខ្លះមកអំពីកងទ័ពសហភាពនឹងខ្លួន មិនអាចយល់គ្នាទូវគ្នាបាន ។ នេះជាហេតុមួយទៀត គួរឲ្យទាហានខេមរជាតិចេះប្រមូលគ្នា ដើម្បីនាំគ្នាទៅការពារប្រជាពលរដ្ឋដោយខ្លួនឯងវិញ ។

បញ្ហាខាងឯកភាពនឹងអសន្តិសុខ សូមអធិប្បាយប្រគេនតែប៉ុណ្ណោះសិនចុះ ។

ខ្ញុំករុណា សូមថ្លែងសេចក្ដីខ្លះ ពិតលោកគ្រូគ្រប់ព្រះអង្គ អំពីលទ្ធិប្រជាធិបតេយ្យរបស់យើង ។ (មានត)